ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

# ក្របខណ្ឌសមត្ថភាពអក្ខរកម្មឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន

## (អ.ឌ.ប.ព.)




“ លើកកម្ពស់ការកសាងពលរដ្ឋឌីជីថល
ដើម្បីសេដ្ឋកិច្ចនិងសង្គមឌីជីថលដ៏រស់រវើក ”

unesco
ស៊ុយអែត
Sverige

# ក្រុមខណ្ឌសមត្ថភាពអក្ខរកម្មឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន

## ( អ.ឌ.ប.ព. )

«លើកកម្ពស់ការកសាងពលរដ្ឋឌីជីថល
ដើម្បីសេដ្ឋកិច្ចនិងសង្គមឌីជីថលដ៏រស់រវើក»

ឆ្នាំ ២០២៤

## អារម្ភកថា



### ឯកឧត្តម ជា វ៉ាន់ដេត
**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព និងការកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាជាប្រទេសមានចំណូលខ្ពស់ក្នុងឆ្នាំ២០៥០។ ក្នុងនោះ រាជរដ្ឋាភិបាលបានកំណត់យកអាទិភាពគន្លឹះចំនួន៥ គឺ **"មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា"** ហើយបច្ចេកវិទ្យាឌីជីថលគឺជាឧបករណ៍ដ៏មានសក្តានុពលសម្រាប់ឆ្លើយតបទៅនឹងបដិវត្តឧស្សាហកម្មទី៤ និងបរិវត្តកម្មឌីជីថលនៃសេដ្ឋកិច្ចនិងសង្គមកម្ពុជា។ ក្នុងន័យនេះ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល គឺជាកត្តាចាំបាច់មិនអាចខ្វះបានក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល។

ដើម្បីចូលរួមសម្រេចគោលដៅនេះ ក្រសួងប្រៃណីយ៍និងទូរគមនាគមន៍ បានសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការលើកកម្ពស់ចំណេះដឹងឌីជីថលរបស់សិស្ស និស្សិត និងប្រជាពលរដ្ឋគ្រប់វ័យជាអាទិ៍តាមរយៈកម្មវិធីផ្សព្វផ្សាយ "កម្ពុជាឆ្ពោះទៅឌីជីថល" (Go Digital Cambodia) កម្មវិធីប្រកួតប្រជែង "បញ្ញវ័ន្តឌីជីថល" (Digital Talents) និងការសាងសង់មជ្ឈមណ្ឌលបច្ចេកវិទ្យាសហគមន៍ (Community Tech Center) នៅតាមវិទ្យាល័យរដ្ឋ ដោយចាប់ផ្តើមពីតំបន់ជនបទ។

យ៉ាងណាមិញ ប្រជាពលរដ្ឋគ្រប់រូបត្រូវមានចំណេះដឹងនិងសមត្ថភាពជាមូលដ្ឋានសំខាន់ៗមួយចំនួន ដើម្បីអាចក្លាយជា **"ពលរដ្ឋឌីជីថល"** និងទាញយកប្រយោជន៍ជាអតិបរិមារពីបច្ចេកវិទ្យាឌីជីថល។ ពលរដ្ឋឌីជីថល មិនត្រឹមតែជាពលរដ្ឋដែលចេះប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងជីវភាពប្រចាំថ្ងៃនោះទេ តែថែមទាំងជាពលរដ្ឋដែលប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដោយប្រសិទ្ធភាព សុវត្ថិភាព និងការទទួលខុសត្រូវ។ ចំណេះដឹងនិងសមត្ថភាពទាំងនេះ ជួយឱ្យពលរដ្ឋគ្រប់រូបចូលរួមក្នុងការកសាងសេដ្ឋកិច្ចនិងសង្គមឌីជីថលបានយ៉ាងសកម្ម ប្រកបដោយភាពជឿជាក់ ព្រមទាំងអាចទប់ស្កាត់និងឆ្លើយតបនឹងបញ្ហាប្រឈមនានាដែលអាចកើតមានលើប្រព័ន្ធអ៊ីនធឺណិត។

ដោយមើលឃើញពីភាពចាំបាច់នេះ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានសហការជាមួយអង្គការយូណេស្កូប្រចាំកម្ពុជា ក្នុងការរៀបចំ “**ក្របខណ្ឌសមត្ថភាពអក្ខរកម្មឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន**” ដើម្បីកំណត់ស្តង់ដាសមត្ថភាពចាំបាច់ដែលពលរដ្ឋកម្ពុជាគ្រប់រូបគួរមាន ស្របតាមស្ថានភាពវិវត្តនៅកម្រិតប្រទេស តំបន់ និងពិភពលោក។ ក្របខណ្ឌសមត្ថភាពអក្ខរកម្មនេះ នឹងក្លាយជាឯកសារយោងមួយសំខាន់ ក្នុងការរៀបចំមុខវិជ្ជាសិក្សាផ្នែកឌីជីថល ការវាយតម្លៃកម្រិតសមត្ថភាព និងការរៀបចំផែនការយុទ្ធសាស្ត្រលើកកម្ពស់កម្រិតអក្ខរកម្មឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាននៅគ្រប់កម្រិត។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា អ្នកពាក់ព័ន្ធទាំងអស់នឹងចូលរួមប្រើប្រាស់និងផ្សព្វផ្សាយក្របខណ្ឌនេះ ក្នុងកិច្ចការពង្រឹងអក្ខរកម្មឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន និងការកសាងពលរដ្ឋឌីជីថលក្នុងគ្រប់រូបភាព ដើម្បីចូលរួមប្រែក្លាយសេដ្ឋកិច្ចនិងសង្គមកម្ពុជាទៅជាសេដ្ឋកិច្ចនិងសង្គមឌីជីថលដ៏រស់រវើក។

ថ្ងៃព្រហស្បតិ៍ ១២កើតខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៤

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**ជា វ៉ាន់ដេត**

# បញ្ជីពាក្យកាត់

| | |
|---|---|
| **អ.ប.ព.** | អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយនិងព័ត៌មាន |
| **អ.ឌ.** | អក្ខរកម្មឌីជីថល |
| **អ.ឌ.ប.ព.** | អក្ខរកម្មឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន |
| **5G** | បច្ចេកវិទ្យាទូរសព្ទចល័តជំនាន់ទី៥ (The Fifth Generation of Mobile Technologies) |
| **AI** | បញ្ញាសិប្បនិម្មិត (Artificial Intelligence) |
| **AR** | បច្ចេកវិទ្យាតថភាពបន្ថែម (Augmented reality) |
| **cc** | ការរក្សាសិទ្ធិបែបស៊ីស៊ី (Creative Commons) |
| **DigComp** | ក្របខណ្ឌសមត្ថភាពឌីជីថលសម្រាប់ពលរដ្ឋរបស់សហភាពអឺរ៉ុប (The European Digital Competence Framework for Citizens) |
| **DEQ** | សមត្ថភាពក្នុងការឈ្វេងយល់ ឆ្លើយតប និងគ្រប់គ្រងអារម្មណ៍ក្នុងពិភពឌីជីថល (Digital Emotional Intelligence) |
| **DMIL** | ក្របខណ្ឌសមត្ថភាពអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយនិងព័ត៌មានឌីជីថល (របស់សិង្ហបុរី) (Digital Media and Information Literacy Framework) |
| **IEC** | ព័ត៌មាន អប់រំ និងទំនាក់ទំនង (Information, Education and Communication) |
| **IoT** | អ៊ីនធឺណិតនៃវត្ថុ (Internet of Things) |
| **OPAC** | កាតាឡុកបណ្ណាល័យអនឡាញ (Online Public Access Catalog) |
| **SDGs** | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (The Sustainable Development Goals) |
| **SMS** | សារខ្លីតាមប្រព័ន្ធទូរសព្ទចល័ត (Short Message Service) |
| **VR** | បច្ចេកវិទ្យាតថភាពនិម្មិត (Virtual Reality) |

# មាតិកា


អារម្ភកថា i
បញ្ជីពាក្យកាត់ iv

១

**១. សេចក្តីផ្តើម ១**
១.១. ការកសាងពលរដ្ឋឌីជីថល ២
១.២. បញ្ហាប្រឈមនានាដែលកើតចេញពីការវិវត្តនៃបច្ចេកវិទ្យា ៤
១.៣. ភាពដាច់ដោយឡែកពីគ្នានៃកម្មវិធីលើកកម្ពស់ អ.ឌ.ប.ព. នៅកម្ពុជា ៧

២

**២. វិធីសាស្ត្ររៀបចំក្របខណ្ឌសមត្ថភាព អ.ឌ.ប.ព. ៨**
២.១. ការប្រៀបធៀបក្របខណ្ឌសមត្ថភាព អ.ឌ.ប.ព. ថ្នាក់តំបន់និងសកលលោក ៩
២.២. ការវាយតម្លៃស្ថានភាព ការសិក្សាស្រាវជ្រាវ និងកិច្ចពិគ្រោះយោបល់ ១១
២.៣. គោលការណ៍ និងគុណតម្លៃនៃក្របខណ្ឌសមត្ថភាព អ.ឌ.ប.ព. ១៣

៣

**៣. ក្របខណ្ឌសមត្ថភាព អ.ឌ.ប.ព. កម្ពុជា ១៤**
៣.១.និយមន័យនៃអក្ខរកម្មឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន ១៤
៣.២.ចង្កោមសមត្ថភាព អ.ឌ.ប.ព. កម្ពុជា ១៥

៤

**៤. ការប្រើប្រាស់ក្របខណ្ឌសមត្ថភាព អ.ឌ.ប.ព. ៣១**
៤.១. ការបញ្ចូល អ.ឌ.ប.ព. ទៅក្នុងការអប់រំនៅតាមគ្រឹះស្ថានសាធារណៈនិងឯកជន ៣២
៤.២. ការវាយតម្លៃកម្មវិធី ឬ កម្មវិធីសិក្សាដែលមានស្រាប់ពាក់ព័ន្ធនឹង អ.ឌ. និងអ.ប.ព. ៣២
៤.៣. ការអភិវឌ្ឍគោលនយោបាយ ឬ យុទ្ធសាស្ត្រ ៣៣

៥

**៥. សេចក្តីសន្និដ្ឋាន ៣៣**

**ឧបសម្ព័ន្ធ សន្ទានុក្រម ៣៤**

# ១. សេចក្តីផ្តើម

ក្របខណ្ឌសមត្ថភាពអក្ខរកម្មឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន (**អ.ឌ.ប.ព.**) ត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការបន្ទាន់របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកសាង "ពលរដ្ឋឌីជីថល" ដែលជាសសរស្តម្ភមួយទ្រទ្រង់ដល់ដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថលដ៏រស់រវើក។ ក្របខណ្ឌនេះគឺជាស្តង់ដាមូលដ្ឋានរួមមួយ ដែលអាចយកទៅប្រើប្រាស់ដើម្បីអភិវឌ្ឍសមត្ថភាពរបស់ប្រជាពលរដ្ឋឆ្លើយតបទៅនឹងកាលានុវត្តភាព និងបញ្ហាប្រឈមជាច្រើន ដែលកំពុងកើតមានឡើងដោយសារការវិវត្តឥតឈប់ឈររបស់បច្ចេកវិទ្យា។ បច្ចេកវិទ្យាទំនើបចុងក្រោយ ជាអាទិ៍ បញ្ញាសិប្បនិម្មិត ប្លុកឆេន បច្ចេកវិទ្យាក្លោដ ទិន្នន័យធំ បច្ចេកវិទ្យាតថភាពនិម្មិត បច្ចេកវិទ្យាតថភាពបន្ថែម អ៊ីនធឺណិតនៃវត្ថុ និងបច្ចេកវិទ្យាទូរសព្ទចល័តជំនាន់ទី៥ (5G) បាននាំមកនូវកាលានុវត្តភាពជាច្រើនដូចជា ការពង្រីកវិសាលភាពនិងបង្កើនគុណភាពនៃការប្រាស្រ័យទាក់ទងគ្នា ការបង្កើនសន្តិសុខនិងសុវត្ថិភាពសាធារណៈ ការពង្រីកទីផ្សារការបង្កើតការងារថ្មីៗ និងការលើកកម្ពស់ប្រសិទ្ធភាព ផលិតភាព សហគ្រិនភាព និងនវានុវត្តន៍ធុរកិច្ច។ ទន្ទឹមនឹងនេះការចែកចាយព័ត៌មានមិនពិត ការធ្លាក់ចុះនៃប្រព័ន្ធផ្សព្វផ្សាយអាជីពបែបប្រពៃណី ផលប៉ះពាល់ដល់សិទ្ធិបុគ្គលនិងឯកជនភាព កំណើនឥរិយាបថអវិជ្ជមាននិងការធ្លាក់ចុះផ្នែកសីលធម៌ និងកំណើនអសន្តិសុខឌីជីថលដោយសារការប្រើប្រាស់បច្ចេកវិទ្យាដែលលេចឡើងថ្មីៗដូចជា បញ្ញាសិប្បនិម្មិត បច្ចេកវិទ្យាបច្ចេកវិទ្យាប្លុកឆេន បច្ចេកវិទ្យាក្លោដ បានក្លាយជាបញ្ហាប្រឈមថ្មីដែលភាគីពាក់ព័ន្ធត្រូវយកចិត្តទុកដាក់ដោះស្រាយ។

ជាក់ស្តែងណាស់ការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃបញ្ញាសិប្បនិម្មិតនាពេលបច្ចុប្បន្ន បានធ្វើឱ្យមានកំណើនព័ត៌មានខុស ព័ត៌មានមិនពិត ការឃ្លាំមើល ការរំលោភលើឯកជនភាព និងការរើសអើងយេនឌ័រជាដើម។ មូលហេតុទាំងអស់នេះ ធ្វើឱ្យអក្ខរកម្មឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន រឹតតែចាំបាច់ក្នុងការផ្តល់ជូនបុគ្គលម្នាក់ៗនូវចំណេះដឹង ជំនាញ អាកប្បកិរិយា និងគម្លៃនានា ដែលមិនត្រឹមតែជួយការពារខ្លួនពីហានិភ័យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់សិទ្ធិអំណាចឱ្យពួកគេអាចទាញយកអត្ថប្រយោជន៍ពីបញ្ញាសិប្បនិម្មិត បានទៀតផង។

ប្រជាពលរដ្ឋដែលមានសមត្ថភាព **អ.ឌ.ប.ព.** ស្របតាមក្របខណ្ឌអក្ខរកម្មនេះ នឹងមានលទ្ធភាពកំណត់ដឹងហានិភ័យ ចៀសវាងគ្រោះថ្នាក់ និងទាញយកប្រយោជន៍ពិតប្រាកដពីការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់សម្រួលដល់ជីវភាពប្រចាំថ្ងៃ ការប្រកបអាជីវកម្ម ការប្រាស្រ័យទាក់ទង ការចូលរួមក្នុងសង្គម ការសិក្សា

ពេញមួយជីវិត និងការកសាងសហគ្រិនភាព។ ស្ថាប័នដែលមានតួនាទីលើកកម្ពស់ **អ.ឌ.ប.ព.** ក៏អាចយកក្របខណ្ឌនេះទៅធ្វើជាមូលដ្ឋានក្នុងការវាស់ស្ទង់សមត្ថភាពក្រុមគោលដៅឱ្យបានជាក់លាក់ និងរៀបចំយុទ្ធសាស្ត្រលើកកម្ពស់ **អ.ឌ.ប.ព.** ប្រកបដោយប្រសិទ្ធភាពទៅតាមតម្រូវការនិងស្ថានភាពជាក់ស្តែងនៅកម្ពុជា។

## ១.១. ការកសាងពលរដ្ឋឌីជីថល

រាជរដ្ឋាភិបាលបានដាក់ចេញក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ និងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ ដែលបានបង្ហាញពីចក្ខុវិស័យវែងឆ្ងាយក្នុងការប្រែក្លាយសេដ្ឋកិច្ចនិងសង្គមកម្ពុជាទៅជាសេដ្ឋកិច្ចនិងសង្គមឌីជីថលរស់រវើកតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីជំរុញសម្ទុះកំណើនសេដ្ឋកិច្ចថ្មី លើកកម្ពស់សុខុមាលភាពសង្គម និងផ្តល់សេវាសាធារណៈកាន់តែប្រសើរឡើង។ ក្នុងការសម្រេចគោលបំណងទាំងនេះ ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលផ្តោតលើសមាសធាតុចំនួន៥ ដែលចែកចេញជាមូលដ្ឋានគ្រឹះចំនួន២ គឺ ១) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថល និង ២) ការកសាងទំនុកចិត្តនិងភាពជឿជាក់លើប្រព័ន្ធឌីជីថល និងសសរស្តម្ភចំនួន៣ គឺ ១) ការកសាងពលរដ្ឋឌីជីថល ២) ការកសាងរដ្ឋាភិបាលឌីជីថល និង ៣) ការជំរុញធុរកិច្ចឌីជីថល (ដូចមានក្នុងរូបភាពទី១)។ ទន្ទឹមនឹងនេះ យុទ្ធសាស្ត្រទី៧នៃគោលនយោបាយរដ្ឋាភិបាលឌីជីថលផ្តោតលើការអភិវឌ្ឍមូលធនមនុស្សឌីជីថលដែលក្នុងនោះ ការលើកកម្ពស់អក្ខរកម្មឌីជីថលដល់គ្រប់តួអង្គសង្គមជាអាទិភាពចាំបាច់ក្នុងការកាត់បន្ថយគម្លាតឌីជីថលនិងជំរុញការប្រើប្រាស់សេវារដ្ឋាភិបាលឌីជីថល។

លើសពីនេះ យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដែលរាជរដ្ឋាភិបាលបានដាក់ចេញបានកំណត់ "ការកសាងរដ្ឋាភិបាលឌីជីថលនិងពលរដ្ឋឌីជីថល" ជាមុំទី១នៃបញ្ចកោណទី៥ ដើម្បីសម្រួចយកកិច្ចការអាទិភាពសម្រាប់អនុវត្តក្នុងនីតិកាលទី៧នៃរដ្ឋសភា (ដូចមានក្នុងរូបភាពទី២)។ ការណ៍នេះបង្ហាញកាន់តែច្បាស់ថា ពលរដ្ឋឌីជីថល គឺជាកត្តាអាទិភាពដែលចូលរួមកំណត់ជោគជ័យក្នុងការបង្កើនប្រសិទ្ធភាពសេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថលនៅកម្ពុជា។

រូបភាពទី១. គ្រឹះនិងសសរស្តម្ភក្នុងការកសាងសេដ្ឋកិច្ចនិងសង្គមឌីជីថល (២០២១-២០៣៥)




រូបភាពទី២. គំនូរបំប្រួញស្តីពី «យុទ្ធសាស្ត្របញ្ចកោណ - ដំណាក់កាលទី១»



គិតត្រឹមឆ្នាំ២០២០ នៅពេលដែលកម្ពុជាចាប់ផ្ដើមរៀបចំក្របខណ្ឌគោលនយោបាយធ្វើបរិវត្តកម្មឌីជីថល សេដ្ឋកិច្ច និងសង្គម ប្រជាជនកម្ពុជា ៣២% អាចប្រើប្រាស់បច្ចេកវិទ្យាឌីជីថលកម្រិតមូលដ្ឋាន ៥% មានជំនាញកម្រិតមធ្យម និង ១% មានជំនាញកម្រិតខ្ពស់។ ក្នុងរយៈពេលក្រោយមក វិធានការជាច្រើនត្រូវបានដាក់ចេញក្នុងការបង្កើនអក្ខរកម្មនិងជំនាញឌីជីថលក្នុងគ្រប់មជ្ឈដ្ឋានប្រកបដោយបរិយាបន្ន តែទោះជាយ៉ាងណា កម្ពុជានៅមានតម្រូវការបង្កើនអក្ខរកម្មនិងជំនាញឌីជីថលថែមទៀត ដើម្បីអនុវត្តគោលនយោបាយបរិវត្តកម្មឌីជីថលរបស់ខ្លួននិងបង្កើនភាពប្រកួតប្រជែងក្នុងទីផ្សារតំបន់។

ការប្រែក្លាយពលរដ្ឋកម្ពុជាជាពលរដ្ឋឌីជីថលទាមទារការដាក់ចេញនូវវិធានការគោលនយោបាយច្រើនប្រទាក់ក្រឡាគ្នា ដើម្បីលើកកម្ពស់ **អ.ឌ.ប.ព.** បានគ្រប់កម្រិត គ្រប់ផ្នែក តាមរយៈការបំពាក់បំប៉នបំណិនវិជ្ជាជីវៈក្នុងប្រព័ន្ធអប់រំផ្លូវការ ការបណ្ដុះបណ្ដាលក្រៅប្រព័ន្ធ និងកម្មវិធីគាំទ្រតាមវិស័យជាដើម។ ក្នុងន័យនេះ គ្រប់ភាគីពាក់ព័ន្ធដែលរៀបចំការបណ្ដុះបណ្ដាល យុទ្ធសាស្ត្រ ឬ ផែនការលើកកម្ពស់អក្ខរកម្មឌីជីថល និងវាយតម្លៃកម្រិត **អ.ឌ.ប.ព.** របស់បុគ្គលម្នាក់ៗ ត្រូវការក្របខណ្ឌសមត្ថភាព **អ.ឌ.ប.ព.** រួមមួយ ដែលឆ្លុះបញ្ចាំងពីតម្រូវការសមត្ថភាព **អ.ឌ.ប.ព.** ជាក់លាក់នៅក្នុងបរិបទសង្គមកម្ពុជាបច្ចុប្បន្ន។ ហេតុនេះ ការរៀបចំក្របខណ្ឌសមត្ថភាព **អ.ឌ.ប.ព.** សម្រាប់កម្ពុជា គឺជាកត្តាចាំបាច់ និងជាគន្លឹះសំខាន់ដើម្បីលើកកម្ពស់ **អ.ឌ.ប.ព.** ក្នុងកម្រិតស្ដង់ដាសមត្ថភាពរួមដែលអាចវាស់វែងបាន និងធានាសង្គតិភាពនិងប្រសិទ្ធភាពនៃកម្មវិធីអភិវឌ្ឍសមត្ថភាព **អ.ឌ.ប.ព.** ដែលបាននិងកំពុងរៀបចំដោយអ្នកពាក់ព័ន្ធផ្សេងៗ។

## ១.២. បញ្ហាប្រឈមនានាដែលកើតចេញពីការវិវត្តនៃបច្ចេកវិទ្យា

ស្របពេលដែលកម្រិតអក្ខរកម្មឌីជីថលរបស់ប្រជាពលរដ្ឋកម្ពុជានៅមានកម្រិត អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានមិនទាន់មានការវាស់វែងបានច្បាស់លាស់នៅឡើយទេ។ ទោះជាយ៉ាងណា **អ.ឌ.ប.ព.** ជាសមត្ថភាពដែលពលរដ្ឋគ្រប់រូបគួរមាននៅក្នុងសង្គមឌីជីថលនាពេលបច្ចុប្បន្ននិងអនាគត ដើម្បីឆ្លើយតបទៅនឹងហានិភ័យនិងផលប៉ះពាល់អវិជ្ជមានផ្សេងៗដែលអាចកើតមានពីការប្រើប្រាស់អ៊ីនធឺណិតនិងប្រព័ន្ធឌីជីថល។ បញ្ហាទាំងនោះមានដូចជា៖

**ក.** កំណើននៃព័ត៌មានមិនពិតដែលប្រជាពលរដ្ឋអាចទទួលបានយ៉ាងងាយជាទីបំផុតតាមរយៈការចែករំលែកគ្នាយ៉ាងលឿនរហ័សនៅលើបណ្ដាញផ្សព្វផ្សាយសង្គម។ ព័ត៌មានមិនពិតដោយចេតនា ជាព័ត៌មានបង្កើតឡើងក្នុងចេតនាបំភាន់ បង្កឱ្យមានការយល់ច្រលំ ឬ បង្កគ្រោះថ្នាក់តាមបែបណាមួយ។ ការទទួលយកនិងជឿលើព័ត៌មានទាំងនេះអាចនាំឱ្យមានការសម្រេចចិត្តខុស ធ្វើសកម្មភាពខុសឆ្គង និងទទួលរងនូវគ្រោះថ្នាក់នានា។ ព័ត៌មានមិនពិតកំពុងគំរាមកំហែងសន្តិភាពនិងស្ថិរភាពប្រទេសជាច្រើន ក្នុងពិភពលោកយ៉ាងគំហុកចាប់ពីឆ្នាំ២០១៦ មក។ ការអង្កេតមួយនៅប្រទេសសិង្ហបុរី

បង្ហាញថា ប្រជាពលរដ្ឋប្រមាណ ៧៧% បានឃើញព័ត៌មានមិនពិត យ៉ាងហោចម្តងម្កាល តាមរយៈបណ្តាញហ្វេសប៊ុក (Facebook) ឬ វ៉តអាប់ (WhatsApp) មានទាំងការផ្សព្វផ្សាយពីការផ្អាកការផ្តល់សេវាសាធារណៈដោយសារគ្រោះថ្នាក់រថភ្លើងបុកគ្នាជាដើម។[១] ថ្វីបើប្រជាពលរដ្ឋសិង្ហបុរីមានកម្រិត **អ.ឌ.ប.ព.** ខ្ពស់ជាងប្រទេសដទៃនៅតំបន់អាស៊ីអាគ្នេយ៍ក៏ដោយ ក៏មានប្រជាពលរដ្ឋប្រមាណតែ ៥០% ប៉ុណ្ណោះ ដែលទុកចិត្តលើខ្លួនឯងក្នុងការសម្គាល់ថាព័ត៌មានណាជាព័ត៌មានមិនពិត។ ដោយឡែកនៅកម្ពុជា ប្រភពពីក្រសួងព័ត៌មានបានបង្ហាញថា ព័ត៌មានមិនពិតចំនួនប្រមាណ ៤០០០ ករណីត្រូវបានបង្កើតនិងផ្សព្វផ្សាយនៅក្នុងរយៈពេល ៥ឆ្នាំ គិតពីឆ្នាំ២០១៧ ដល់ ឆ្នាំ២០២២។[២] បញ្ហាប្រឈមនេះកំពុងរីករាលដាលខ្លាំងនៅតាមប្រព័ន្ធផ្សព្វផ្សាយបែបថ្មី និងបង្កើតហានិភ័យជាច្រើនចំពោះសេដ្ឋកិច្ច សង្គម និងនយោបាយ។ ក្របខណ្ឌសមត្ថភាព **អ.ឌ.ប.ព.** គឺជាវិធានការមួយដើម្បីឆ្លើយតបចំពោះបញ្ហាទាំងនេះ។

**ខ**. ប្រជាប្រិយភាពនៃបណ្តាញផ្សព្វផ្សាយសង្គម (Social Media) ដែលមានគេប្រើប្រាស់ច្រើនដើម្បីទទួលយកព័ត៌មានបានលឿនរហ័សនិងសម្បូរបែប និងកំណើនប្រជាប្រិយភាពរបស់អ្នកមានឥទ្ធិពលលើបណ្តាញផ្សព្វផ្សាយសង្គម បានធ្វើឱ្យប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណីនិងអ្នកសារព័ត៌មានអាជីពលែងជាទីពេញនិយមនិងត្រូវបាត់បង់បន្តិចម្តងៗ។ ការបាត់បង់គុណភាពនេះគឺជាចន្លោះប្រហោង និងជាចំណុចខ្សោយមួយដែលធ្វើឱ្យព័ត៌មានមិនពិតងាយជ្រៀតចូលនិងរាលដាលក្នុងសង្គម។

**គ**. ការកើនឡើងនៃការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ដូចជាបញ្ញាសិប្បនិម្មិតនិងការប្រើប្រាស់អាល់ហ្គោរីត (Algorithm) ដើម្បីវិភាគឈ្វេងយល់ពីឥរិយាបថនៃការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលបណ្តាលឱ្យអ្នកប្រើប្រាស់ប្រឈមនឹងហានិភ័យដូចជាព័ត៌មានខុស ព័ត៌មានមិនពិត ការឃ្លាំមើលការរំលោភលើឯកជនភាព និងការរើសអើងយេនឌ័រជាដើម និងទទួលរងឥទ្ធិពលនៃការតម្រង់ទិសសកម្មភាព ឬ កែប្រែឥរិយាបទដោយមិនដឹងខ្លួនពីប្រព័ន្ធបច្ចេកវិទ្យាទាំងនេះ។

**ឃ**. អគុណភាពនៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយនិងព័ត៌មាន ដោយសារមាតិកាសម្បូរបែបនិងទាក់ទាញនៅលើថ្នាលតែមួយធ្វើឱ្យអ្នកប្រើប្រាស់ស្វែងរកព័ត៌មានកម្សាន្តហួសហេតុ មិនចាប់យកប្រយោជន៍ពីប្រព័ន្ធផ្សព្វផ្សាយនិងព័ត៌មាន និងមិនអាចផ្តោតលើព័ត៌មានដែលខ្លួនត្រូវការពិតប្រាកដ។ ការដោះស្រាយបញ្ហាទាំងនេះទាមទារនូវការគិតគូរពីឥរិយាបថនិងរបៀបនៃការប្រើប្រាស់បច្ចេកវិទ្យាឱ្យបានត្រឹមត្រូវ ដែលនឹងត្រូវគូសបញ្ជាក់នៅក្នុងក្របខណ្ឌសមត្ថភាព **អ.ឌ.ប.ព.** នេះ។

---

[១] https://www.gov.sg/article/singapores-fight-against-fake-news-what-you-can-do
[២] https://www.information.gov.kh/articles/85203

**៤**. ការកើនឡើងនៃការប្រែក្លាយខ្លួនពីអ្នកប្រើប្រាស់មាតិកាទៅជាអ្នកបង្កើតមាតិកានៅលើថ្នាលឌីជីថលរួម ទាមទារឱ្យមានការគិតគូរជាបន្ទាន់ក្នុងការបង្កើនសមត្ថភាព និងការយល់ដឹងផ្នែកផលិតមាតិកាបន្ថែមទៀតចំពោះអ្នកប្រើប្រាស់ទូទៅ រួមទាំងការរក្សាកម្មសិទ្ធិបញ្ញា ការរក្សាសិទ្ធិឯកជនរបស់បុគ្គល និងការធ្វើយ៉ាងណាឱ្យមាតិកាដែលផលិតមកមិនមែនជាព័ត៌មានមិនពិត ឬ ព័ត៌មានដែលមានលក្ខណៈប៉ះពាល់ដល់អ្នកដទៃ សង្គម ឬ ទំនៀមទម្លាប់ប្រពៃណីជាដើម។

**៥**. ការញៀននឹងបច្ចេកវិទ្យារហូតមានផលប៉ះពាល់អវិជ្ជមានដល់ស្ថានភាពផ្លូវចិត្ត កើតមានជាបន្តបន្ទាប់ ជាពិសេសក្នុងចំណោមយុវវ័យ ដោយសារការពុំដឹងពីវិធីសាស្ត្រប្រើប្រាស់ឱ្យបានត្រឹមត្រូវ។

**៦**. បញ្ហាអត្តសញ្ញាណ ឯកជនភាព និងសន្តិសុខឌីជីថល ជាបញ្ហាដែលអ្នកប្រើប្រាស់ទូទៅកំពុងជួបប្រទះ និងទាមទារឱ្យអ្នកប្រើប្រាស់មានចំណេះដឹងច្បាស់លាស់ក្នុងការរក្សាអត្តសញ្ញាណនិងឯកជនភាពរបស់ខ្លួន ព្រមទាំងការរក្សាសុវត្ថិភាពលើប្រព័ន្ធបច្ចេកវិទ្យា។

**៧**. ស្របពេលជាមួយគ្នានោះដែរ **អ.ឌ.ប.ព.** នឹងត្រូវចូលរួមក្នុងការដោះស្រាយបញ្ហាដូចជាអតុល្យភាពរវាងរបកគំហើញបច្ចេកវិទ្យាថ្មី និងការធ្លាក់ចុះខាងផ្នែកសីលធម៌ជាដើម ធ្វើយ៉ាងណាឱ្យការប្រើប្រាស់ បច្ចេកវិទ្យាមានសណ្តាប់ធ្នាប់ និងបង្កើនការយោគយល់អធ្យាស្រ័យចំពោះគ្នាទៅវិញទៅមក។



## ១.៣. ភាពដាច់ដោយឡែកពីគ្នានៃកម្មវិធីលើកកម្ពស់ អ.ឌ.ប.ព. នៅកម្ពុជា

ខណៈដែលកម្ពុជាត្រូវការការលើកកម្ពស់កម្រិត **អ.ឌ.ប.ព.** ក្នុងប្រទេស ដើម្បីសម្រេចគោលនយោបាយរបស់រាជរដ្ឋាភិបាល និងកាត់បន្ថយហានិភ័យនិងផលអវិជ្ជមានឱ្យនៅកម្រិតទាបបំផុត និងជួយឱ្យប្រជាពលរដ្ឋទទួលបានប្រយោជន៍ពេញលេញពីការប្រើប្រាស់បច្ចេកវិទ្យា ភាគីពាក់ព័ន្ធមិនទាន់មានក្របខណ្ឌសមត្ថភាព **អ.ឌ.ប.ព.** រួមមួយ ដែលឆ្លើយតបនឹងទិដ្ឋភាពជាក់ស្តែងនិងបញ្ហាប្រឈមដូចដែលបានរៀបរាប់ខាងលើនៅឡើយ។ សកម្មភាពលើកកម្ពស់ **អ.ឌ.ប.ព.** និងកម្មវិធីវគ្គបណ្តុះបណ្តាលមានភាពដាច់ដោយឡែកពីគ្នា និងអនុលោមទៅតាមក្របខណ្ឌសមត្ថភាព **អ.ឌ.ប.ព.** ផ្សេងៗគ្នា។ ការប្រើប្រាស់ក្របខណ្ឌផ្សេងៗគ្នានេះបង្កការលំបាកដល់ការវាស់វែងអំពីកម្រិតសមត្ថភាពរបស់ប្រជាពលរដ្ឋក្នុងរូបភាពទូលំទូលាយ ដែលអាចឆ្លុះបញ្ចាំងទិដ្ឋភាពរួមនៃកម្រិតយល់ដឹងរបស់ប្រជាពលរដ្ឋ និងការដាក់ចេញនូវកម្មវិធីលើកកម្ពស់សមត្ថភាពប្រកបដោយប្រសិទ្ធភាព។

បច្ចុប្បន្ន អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយនិងព័ត៌មាន ត្រូវបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធអប់រំផ្លូវការនៃកម្មវិធីសិក្សា ៣ កម្រិត គឺ កម្រិតបឋមសិក្សា កម្រិតមធ្យមសិក្សាបឋមភូមិ និងកម្រិតមធ្យមសិក្សាទុតិយភូមិ។ កម្មវិធីសិក្សាទាំងនេះមានគោលបំណងតម្រង់ទិសសិស្សានុសិស្សលើវិជ្ជាសម្បទា (ចំណេះដឹង) បំណិនសម្បទា (ការប្រើប្រាស់) និងចរិយាសម្បទា (ឥរិយាបថ) នៃការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាននៅក្នុងការសិក្សារៀនសូត្រ ការងារ និងជីវភាពរស់នៅប្រចាំថ្ងៃ។[៣] ការរៀបចំកម្មវិធីសិក្សានិងមេរៀនបានពឹងផ្អែកច្រើនលើក្របខណ្ឌពីប្រទេសសិង្ហបុរីនិងកម្មវិធីបណ្តុះបណ្តាលផ្សេងៗទៀត។

ដោយឡែក ក្នុងការលើកកម្ពស់អក្ខរកម្មឌីជីថលរបស់មន្ត្រីរាជការ បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជាបានប្រើប្រាស់ក្របខណ្ឌអក្ខរកម្មឌីជីថលរបស់សហភាពអឺរ៉ុប DigComp ជាមូលដ្ឋាននៃការរៀបចំកម្មវិធីសិក្សារបស់ខ្លួន។ ក្របខណ្ឌ DigComp ត្រូវបានរៀបចំដើម្បីតម្រូវទៅតាមស្ថានភាពរបស់ប្រទេសអភិវឌ្ឍដែលមានមូលដ្ឋានគ្រឹះចំណេះដឹងមួយចំនួនរួចជាស្រេច ខុសពីទិដ្ឋភាពរបស់កម្ពុជាដែលការយល់ដឹងជាមូលដ្ឋានអំពីព័ត៌មាន ការផ្សព្វផ្សាយ កម្មសិទ្ធិបញ្ញា បញ្ហាឯកជនភាព ជាចំណោទដែលត្រូវយកចិត្តទុកដាក់ដោះស្រាយដើម្បីទ្រទ្រង់ការវិវត្តរបស់សង្គមឌីជីថលដ៏ល្អប្រសើរមួយ។

ស្របពេលជាមួយគ្នានេះ អង្គការក្រៅរដ្ឋាភិបាលនិងស្ថាប័នឯកជនជាច្រើន បាននិងកំពុងរៀបចំកម្មវិធីបណ្តុះបណ្តាលទៅតាមប្រធានបទដោយឡែកៗពីគ្នា អំពីប្រព័ន្ធផ្សព្វផ្សាយ ព័ត៌មាន និងឌីជីថលនេះ

[៣] កម្មវិធីសិក្សាលម្អិតមុខវិជ្ជាបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានសម្រាប់កម្រិតបឋមសិក្សា, កម្រិតមធ្យមសិក្សាបឋមភូមិ, កម្រិតមធ្យមសិក្សាទុតិយភូមិ, ក្រសួង អ.យ.ក. ២០១៨

ដូចជាកម្មវិធីបណ្តុះបណ្តាលអ្នកសារព័ត៌មានស្តីពីសន្តិសុខបច្ចេកវិទ្យានិងទិន្នន័យបើកចំហ[៤] ជាដើម។ ក្រៅពីនេះមានកម្មវិធីលើកកម្ពស់អក្ខរកម្មឌីជីថលនៅតាមសាលារៀនក្នុងក្របខណ្ឌកម្មវិធីទំនួលខុសត្រូវសង្គមរបស់ប្រតិបត្តិករទូរគមនាគមន៍[៥] និងកម្មវិធីបណ្តុះបណ្តាលការសរសេរកូដដល់កុមារតូចក្រៅប្រព័ន្ធ។

កង្វះនូវក្របខណ្ឌ **អ.ឌ.ប.ព.** រួម ដែលឆ្លើយតបនឹងស្ថានភាពនិងតម្រូវការរបស់កម្ពុជា អាចបង្កើតឱ្យមានទិសដៅមិនច្បាស់លាស់ ការអនុវត្តកម្មវិធីមិនមានប្រសិទ្ធភាព ភាពជាន់គ្នាក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាល និងជាពិសេសមិនអាចវាស់ស្ទង់កម្រិតអក្ខរកម្មជាលក្ខណៈជាតិបាន។

យោងទៅលើតម្រូវការបន្ទាន់ក្នុងការគាំទ្រដំណើរការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល និងការដោះស្រាយបញ្ហាប្រឈមនានាខាងលើ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានសហការជាមួយអង្គការយូណេស្កូ រៀបចំក្របខណ្ឌសមត្ថភាព **អ.ឌ.ប.ព.** រួមមួយ ដើម្បីកំណត់ស្តង់ដាសមត្ថភាពក្នុងការកសាងពលរដ្ឋឌីជីថល។ ក្របខណ្ឌសមត្ថភាព **អ.ឌ.ប.ព.** នេះ ត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងបរិបទ របស់កម្ពុជា។ “សមត្ថភាព” និង “ចង្កោមសមត្ថភាព” ចាំបាច់នីមួយៗត្រូវបានកំណត់និងជ្រើសរើសដោយតួអង្គពាក់ព័ន្ធពីគ្រប់វិស័យដែលបានធ្វើកិច្ចការអភិវឌ្ឍន៍សមត្ថភាព **អ.ឌ.ប.ព.** នៅកម្ពុជា ដោយផ្អែកលើស្ថានភាពជាក់ស្តែង គម្លាតសមត្ថភាព និងបញ្ហាប្រឈមក្នុងសង្គម។ ទន្ទឹមនឹងនេះ ក្របខណ្ឌសមត្ថភាពនេះ ក៏បានបន្សុីជាមួយក្របខណ្ឌអន្តរជាតិជាច្រើនដែរ ដើម្បីធានាថាសមត្ថភាព **អ.ឌ.ប.ព.** ដែលបានកំណត់ អាចឆ្លើយតបទៅតាមការវិវត្តរបស់បច្ចេកវិទ្យា តម្រូវការក្នុងតំបន់និងសកលលោក។

## ២. វិធីសាស្ត្ររៀបចំក្របខណ្ឌសមត្ថភាព អ.ឌ.ប.ព.

វិធីសាស្ត្រក្នុងការរៀបចំក្របខណ្ឌសមត្ថភាព **អ.ឌ.ប.ព.** ចាប់ផ្តើមឡើងដោយការសិក្សាទៅលើក្របខណ្ឌអន្តរជាតិនិងប្រទេសក្នុងតំបន់ មានដូចជា ក្របខណ្ឌសមត្ថភាពឌីជីថលសម្រាប់ពលរដ្ឋរបស់សហភាពអ៊ឺរ៉ុប[៦], ក្របខណ្ឌយោងជាសកលស្តីពីបំណិនអក្ខរកម្មឌីជីថលរបស់អង្គការយូណេស្កូសម្រាប់សូចនាករ ៤.៤.២ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព[៧] និងក្របខណ្ឌអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយនិង

---

[៤] Hauswedell, C. (2014). DW Global Media Forum: Open data in Cambodia | DW | 03.07.2014. https://www.dw.com/en/dw-global-media-forum-open-data-in-cambodia/a-17755220

[៥] Smart Axiata. (2020). Cambodia's Digital Literacy and Internet Safety Pilot Program Concludes. Smart. https://www.smart.com.kh/articles/១៩០/cambodias-digital-literacy-and-internet-safety-pilot-program-concludes

[៦] Vuorikari, R., Kluzer, S., & Punie, Y. (2022). DigComp 2.2: The Digital Competence Framework for Citizens - With new examples of knowledge, skills and attitudes. Publications Office of the European Union. https://publications.jrc.ec.europa.eu/repository/handle/JRC128415

[៧] UNESCO. (2018). A global framework of reference on digital literacy skills for indicator 4.4.2. UNESCO Institute for Statistics. https://uis.unesco.org/sites/default/files/documents/ip51-global-framework-reference-digital-literacy-skills-2018-en.pdf

ព័ត៌មានឌីជីថល (DMIL) របស់សិង្ហបុរី[៩]។ ក្របខណ្ឌទាំងនេះត្រូវបានប្រៀបធៀបនិងផ្ទៀងផ្ទាត់ដើម្បីប្រើប្រាស់ជាមូលដ្ឋានក្នុងការវាយតម្លៃស្ថានភាពជាក់ស្តែងនៅកម្ពុជា ការដាក់ចេញនិយមន័យ **អ.ឌ.ប.ព.** និងការកំណត់សមត្ថភាពនិងចង្កោមសមត្ថភាព **អ.ឌ.ប.ព.** សំខាន់ៗ ដែលពលរដ្ឋកម្ពុជាគួរមាន។ ក្របខណ្ឌដែលបានរៀបចំ បានដាក់ឆ្លងសិក្ខាសាលាផ្ទៀងផ្ទាត់លទ្ធផល ដែលមានការចូលរួមយ៉ាងសកម្មពីតួអង្គពាក់ព័ន្ធដើម្បីពិនិត្យនិងផ្តល់យោបល់។

## ២.១. ការប្រៀបធៀបក្របខណ្ឌសមត្ថភាព អ.ឌ.ប.ព. ថ្នាក់តំបន់និងសកលលោក

ក្របខណ្ឌសមត្ថភាព DigComp 2.2 ផ្តោតសំខាន់ទៅលើសមត្ថភាពឌីជីថល ដែលជាសមត្ថភាពសំខាន់សម្រាប់ការសិក្សាពេញមួយជីវិត រួមមានចំណេះដឹង ជំនាញ និងឥរិយាបថដើម្បីប្រើប្រាស់ឧបករណ៍និងបច្ចេកវិទ្យាឌីជីថលប្រកបដោយប្រសិទ្ធភាព។ ក្របខណ្ឌសមត្ថភាពនេះ លើកឡើងពីបរិបទនៅក្នុងបណ្តាប្រទេសសហភាពអឺរ៉ុប ដែលជាប្រទេសមានប្រាក់ចំណូលខ្ពស់និងការអភិវឌ្ឍផ្នែកបច្ចេកវិទ្យា។ គោលបំណងនៃក្របខណ្ឌសមត្ថភាពនេះ គឺដាក់ចេញនូវសមត្ថភាពឌីជីថលសម្រាប់ពលរដ្ឋក្នុងសហភាពអឺរ៉ុប ដើម្បីសម្រេចបាននូវគោលដៅទាក់ទងនឹងអាជីព ការសិក្សា និងការចូលរួមនៅក្នុងសង្គម។ ក្របខណ្ឌនេះ បានបែងចែកសមត្ថភាពជា ៥ ចង្កោមសំខាន់ៗ រួមមាន៖ ១) អក្ខរកម្មព័ត៌មាននិងទិន្នន័យ ២) ការប្រាស្រ័យទាក់ទងនិងកិច្ចសហប្រតិបត្តិការ ៣) ការបង្កើតមាតិកាឌីជីថល ៤) សុវត្ថិភាព និង៥)ការដោះស្រាយបញ្ហា។ តាមរយៈចង្កោមទាំង៥នេះ ក្របខណ្ឌ DigComp 2.2 បានកំណត់សមត្ថភាពចំនួន ២១ ដែលសមត្ថភាពនីមួយៗមាន ៤ កម្រិត គឺ កម្រិតមូលដ្ឋាន កម្រិតមធ្យម កម្រិតខ្ពស់ និងកម្រិតឯកទេស។ ក្របខណ្ឌសមត្ថភាពនេះត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅសហភាពអឺរ៉ុប និងតាមបណ្តាប្រទេសអភិវឌ្ឍជាច្រើនទៀត។

ក្របខណ្ឌយោងជាសកលស្តីពីបំណិនអក្ខរកម្មឌីជីថលរបស់អង្គការយូណេស្កូសម្រាប់សូចនាករ ៤.៤.២ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព បានសិក្សាពីតម្រូវការជាក់ស្តែងទៅលើជំនាញអក្ខរកម្មឌីជីថលនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍនិងប្រទេសអភិវឌ្ឍ ក្នុងគោលបំណងធ្វើជាមូលដ្ឋាន ដើម្បីសម្រេចបាននូវសូចនាករ ៤.៤.២. នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលវាស់អំពីភាគរយនៃយុវជន ឬ មនុស្សពេញវ័យដែលមានបំណិនអក្ខរកម្មឌីជីថល យ៉ាងហោចណាស់ក្នុងកម្រិតអប្បបរមា។ ក្របខណ្ឌនេះ បានស្នើឱ្យបែងចែកសមត្ថភាពជា ៧ ចង្កោមធំៗ រួមមាន៖ ១) ប្រតិបត្តិការឧបករណ៍ឌីជីថលនិងសុសវែរ

[៩] Ministry of Communications and Information. (2018). Digital Media and Information Literacy Framework. https://www.mci.gov.sg/files/mci%20dmil%20framework.pdf

២) អក្ខរកម្មព័ត៌មាននិងទិន្នន័យ ៣) ការប្រាស្រ័យទាក់ទងនិងកិច្ចសហប្រតិបត្តិការ ៤) ការបង្កើតមាតិកាឌីជីថល ៥) សុវត្ថិភាព ៦) ការដោះស្រាយបញ្ហា និង៧) សមត្ថភាពពាក់ព័ន្ធនឹងអាជីព។ ក្របខណ្ឌនេះបានកំណត់សមត្ថភាពចំនួន ២៦ ប៉ុន្តែការរៀបចំនេះមិនបានបែងចែកកម្រិតសមត្ថភាពនោះទេ ដោយមូលហេតុថា កម្រិតសមត្ថភាពមានភាពខុសប្លែកគ្នាទៅតាមបរិបទនិងស្ថានភាពប្រទេសនីមួយៗ។

ក្របខណ្ឌអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយនិងព័ត៌មានឌីជីថល (DMIL) របស់សិង្ហបុរី មានគោលបំណងផ្តល់នូវក្របខណ្ឌទូលំទូលាយមួយ ដើម្បីបង្ហាញផ្លូវដល់ស្ថាប័នអប់រំសាធារណៈក្នុងការលើកកម្ពស់សមត្ថភាពប្រជាជនឱ្យចេះប្រើប្រាស់ព័ត៌មានប្រកបដោយការយល់ដឹងគ្រប់គ្រាន់ ដោយផ្តោតទៅលើលទ្ធផលចំនួន ៥ គឺ ១) សម្គាល់បាននូវអត្ថប្រយោជន៍ ហានិភ័យ និងសក្តានុពលបច្ចេកវិទ្យា ២) យល់ពីដំណើរការនៃថ្នាលអនឡាញនិងថ្នាលឌីជីថល ៣) យល់ពីរបៀបប្រើប្រាស់ព័ត៌មានប្រកបដោយការទទួលខុសត្រូវ ៤) ចេះពីរបៀបការពារខ្លួននៅលើអ៊ីនធឺណិត និង៥)ឈ្វេងយល់ពីរបៀបប្រើប្រាស់បច្ចេកវិទ្យាឌីជីថលប្រកបដោយសុវត្ថិភាព និងការទទួលខុសត្រូវ។

### តារាង១៖ ការប្រៀបធៀបក្របខណ្ឌអក្ខរកម្មឌីជីថលថ្នាក់តំបន់និងសកលលោក

| ក្របខណ្ឌ DigComp 2.2 | ក្របខណ្ឌរបស់អង្គការយូណេស្កូ | ក្របខណ្ឌ DMIL របស់សិង្ហបុរី |
|---|---|---|
| ចង្កោមសមត្ថភាពមានចំនួន ៥ រួមមាន៖<br>១. អក្ខរកម្មព័ត៌មាន និងទិន្នន័យ<br>២. ការប្រាស្រ័យទាក់ទង និង កិច្ចសហប្រតិបត្តិការ<br>៣. ការបង្កើតមាតិកាឌីជីថល<br>៤. សុវត្ថិភាព<br>៥. ការដោះស្រាយបញ្ហា | ចង្កោមសមត្ថភាពមានចំនួន ៧ រួមមាន៖<br>១. ប្រតិបត្តិការឧបករណ៍ឌីជីថល និងសុសវែរ<br>២. អក្ខរកម្មព័ត៌មាននិងទិន្នន័យ<br>៣. ការប្រាស្រ័យទាក់ទង និង កិច្ចសហប្រតិបត្តិការ<br>៤. ការបង្កើតមាតិកាឌីជីថល<br>៥. សុវត្ថិភាព<br>៦. ការដោះស្រាយបញ្ហា<br>៧. សមត្ថភាពពាក់ព័ន្ធនឹងអាជីព | លទ្ធផលរំពឹងទុកមានចំនួន ៥ រួមមាន៖<br>១. សម្គាល់បាននូវអត្ថប្រយោជន៍ ហានិភ័យនិងសក្តានុពលនៃ បច្ចេកវិទ្យា<br>២. យល់ពីដំណើរការនៃថ្នាល អនឡាញ និងថ្នាលឌីជីថល<br>៣. យល់ពីរបៀបប្រើប្រាស់ព័ត៌មាន ប្រកបដោយការទទួលខុសត្រូវ<br>៤. ចេះពីរបៀបការពារខ្លួននៅលើ អ៊ីនធឺណិត<br>៥. ឈ្វេងយល់ពីរបៀបប្រើប្រាស់ បច្ចេកវិទ្យាឌីជីថលប្រកបដោយ សុវត្ថិភាពនិងការទទួលខុសត្រូវ |

## ២.២. ការវាយតម្លៃស្ថានភាព ការសិក្សាស្រាវជ្រាវ និងកិច្ចពិគ្រោះយោបល់

បន្ថែមពីលើការសិក្សាក្របខណ្ឌអក្ខរកម្មឌីជីថលថ្នាក់តំបន់និងសកលលោក ក្របខណ្ឌសមត្ថភាព **អ.ឌ.ប.ព.**នេះ ត្រូវបានបង្កើតឡើងតាមរយៈការសិក្សាស្ថានភាព ការស្ទង់មតិទាំងតាមវិធីសាស្ត្រគុណវិស័យ និងបរិមាណវិស័យ និងការរៀបចំសិក្ខាសាលាផ្ទៀងផ្ទាត់លទ្ធផលនិងពិគ្រោះយោបល់ ដើម្បីឈ្វេងយល់ពីស្ថានភាព **អ.ឌ.ប.ព.** នៅកម្ពុជា គម្លាតសមត្ថភាព និងតម្រូវការសមត្ថភាពឆ្លើយតបបញ្ហាប្រឈមជាក់ស្តែងនៅកម្ពុជា។ សកម្មភាពទាំងអស់នេះមានការចូលរួមពីតួអង្គពាក់ព័ន្ធដែលធ្វើការលើការលើកកម្ពស់ អ.ឌ.ប.ព. ចំនួន ៥៧រូប ជាតំណាងក្រសួង ស្ថាប័នរាជរដ្ឋាភិបាល សង្គមស៊ីវិល អ្នកធ្វើការក្នុងវិស័យអប់រំ ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល ក្រុមយុវជន ក្រុមជនជាតិភាគតិច និងអង្គការជនមានពិការភាព។

ការស្ទង់មតិត្រូវបានរៀបចំឡើងដោយប្រើប្រាស់ក្របខណ្ឌអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយនិងព័ត៌មានរបស់អង្គការយូណេស្កូ និងក្របខណ្ឌអក្ខរកម្មឌីជីថលរបស់សហភាពអឺរ៉ុប (DigComp ២.២) ជាមូលដ្ឋានក្នុងការដាក់ចេញកម្រងសំណួរកំណត់អំពីចង្កោមសមត្ថភាព និងឥរិយាបថដែលប្រជាពលរដ្ឋកម្ពុជាគួរមាន។ សមត្ថភាពលើបច្ចេកវិទ្យាថ្មីៗ ដូចជា បញ្ញាសិប្បនិម្មិតក៏បានជ្រើសរើសយកមកស្ទង់មតិផងដែរ។ សំណួរស្ទង់មតិបានស្នើឱ្យអ្នកចូលរួមដាក់ពិន្ទុទៅលើភាពចាំបាច់នៃសមត្ថភាព **អ.ឌ.ប.ព.** ក្នុងចន្លោះពី ១ ដល់ ៥។ លទ្ធផលនៃការស្ទង់មតិនេះត្រូវបានជ្រើសរើសនិងយកមករៀបចំ រួចវិភាគថាសមត្ថភាព **អ.ឌ.ប.ព.** ណាដែលមានមធ្យមភាគច្រើនជាងគេ ដើម្បីយកមកចងក្រងក្នុងបញ្ជីចង្កោមសមត្ថភាព **អ.ឌ.ប.ព.**។ ឧទាហរណ៍ នៅក្នុងចង្កោមសមត្ថភាពស្តីពីការប្រើប្រាស់ឧបករណ៍ឌីជីថលនិងសុសវែរ តួអង្គពាក់ព័ន្ធបានផ្តល់ពិន្ទុច្រើនលើភាពចាំបាច់នៃឧបករណ៍ឌីជីថលនិងសុសវែរតាមតម្រូវការរបស់ស្ថាប័ន ជាជាងឧបករណ៍ឌីជីថលនិងសុសវែរដែលមានប្រជាប្រិយភាពលើទីផ្សារ និងបានផ្តល់ពិន្ទុច្រើនលើភាពចាំបាច់នៃក្រមសីលធម៌ក្នុងការជ្រើសរើសសុសវែរដែលមានអាជ្ញាបណ្ណ ជាជាងចំណេះដឹងក្នុងការលួចប្រើសុសវែរដើម្បីកាត់បន្ថយចំណាយជាដើម។ល។

ក្របខណ្ឌសមត្ថភាព **អ.ឌ.ប.ព.** ត្រូវបានរៀបចំនិងពិនិត្យឡើងវិញក្នុងសិក្ខាសាលាផ្ទៀងផ្ទាត់លទ្ធផលនិងពិគ្រោះយោបល់ ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់នូវចង្កោមសមត្ថភាព ដែលចាំបាច់ត្រូវដាក់បញ្ចូលក្នុងក្របខណ្ឌនេះ។ តាមរយៈសិក្ខាសាលា តួអង្គពាក់ព័ន្ធបានកំណត់និយមន័យ **អ.ឌ.ប.ព.** ក្នុងបរិបទកម្ពុជាដែលស្របជាមួយនឹងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថល វាយតម្លៃជារួមអំពីប្រព័ន្ធអេកូឡូស៊ី **អ.ឌ.ប.ព.** នៅកម្ពុជា កំណត់តួអង្គពាក់ព័ន្ធសំខាន់ៗ និងអ្នកផ្តល់សេវាលើកកម្ពស់ **អ.ឌ.ប.ព.** និងកំណត់គោលការណ៍និងគុណតម្លៃជាមូលដ្ឋាននៃការបង្កើតក្របខណ្ឌសមត្ថភាព **អ.ឌ.ប.ព.** នេះផងដែរ។

អង្គការយូណេស្កូកំណត់និយមន័យ **អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយនិងព័ត៌មាន** (**អ.ប.ព.**) ថាជាសំណុំសមត្ថភាពរបស់បុគ្គលក្នុងការអាក់សេស, ប្រើប្រាស់, ជ្រើសរើស, វាយតម្លៃ, រៀបចំគ្រប់គ្រង, ចែករំលែកខ្លឹមសារព័ត៌មាន និងបង្កើតមាតិកាឌីជីថលគ្រប់ទម្រង់ ប្រកបដោយការត្រិះរិះពិចារណា ប្រសិទ្ធភាព និងសីលធម៌ក្នុងគោលបំណងផ្សេងៗ។ បន្ថែមពីលើនេះ **អ.ប.ព.** ក៏មានន័យថាជាការយល់ដឹងអំពីតួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយនិងបញ្ហាពាក់ព័ន្ធនឹងព័ត៌មាន ដើម្បីចូលរួមក្នុងក្របខណ្ឌករណីយកិច្ចប្រជាពលរដ្ឋប្រកបដោយការទទួលខុសត្រូវផងដែរ។ រីឯ **អក្ខរកម្មឌីជីថល** (**អ.ឌ.**) គឺជាសមត្ថភាពក្នុងការប្រើប្រាស់ឧបករណ៍ឌីជីថលប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព ការទទួលខុសត្រូវ និងភាពវិជ្ជមាន ដើម្បីបង្កើត ចែករំលែកឈ្វេងយល់ និងវាយតម្លៃមាតិកាឌីជីថលក្នុងគោលបំណងផ្សេងៗ។ **អ.ឌ.** ក៏មានន័យថាជាការយល់ដឹងអំពីដំណើរការរបស់ប្រព័ន្ធឌីជីថល ដើម្បីជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងកាត់បន្ថយហានិភ័យ។ ទន្ទឹមនឹងនេះ ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ បានកំណត់និយមន័យ **អក្ខរកម្មឌីជីថល** (**អ.ឌ.**) ថា "ជំនាញដែលជំរុញសមត្ថភាពឌីជីថលនិងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ សម្រាប់ការសិក្សា រៀនសូត្រ កម្សាន្ត ការងារ និងការប្រាស្រ័យទាក់ទង"។ និយមន័យដែលកំណត់នៅក្នុង**ក្របខណ្ឌសមត្ថភាព អ.ឌ.ប.ព.** (**ផ្នែកទី៣**) មានសង្គតិភាពជាមួយនឹងនិយមន័យរបស់អង្គការយូណេស្កូ និងនិយមន័យរបស់ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ប៉ុន្តែសង្កត់ធ្ងន់លើចំណុចពាក់ព័ន្ធនឹងកិច្ចការអាទិភាពដែលត្រូវយកចិត្តទុកដាក់ជាបន្ទាន់នៅកម្ពុជាគឺ ការត្រិះរិះពិចារណា សុវត្ថិភាព សីលធម៌ បរិយាបន្ន និងការទទួលខុសត្រូវ។ ចំណុចទាំងនេះត្រូវបានស្នើបន្ថែមដោយតួអង្គពាក់ព័ន្ធ ក្នុងដំណើរការប្រឹក្សាយោបល់។

ទោះបីជានិយមន័យ **អ.ឌ.** និង **អ.ប.ព.** ត្រូវបានពិភាក្សានិងកំណត់ដាច់ដោយឡែកពីគ្នាក៏ដោយ ការរៀបចំក្របខណ្ឌសមត្ថភាពនៃប្រព័ន្ធទាំងពីរនេះមិនគួរផ្តាច់ចេញពីគ្នាឡើយដោយមូលហេតុ ១)ការវិវត្តនៃការរួមបញ្ចូលគ្នានៃបច្ចេកវិទ្យាប្រព័ន្ធផ្សព្វផ្សាយនិងព័ត៌មាននិងប្រព័ន្ធឌីជីថល ក៏ដូចជាសារៈសំខាន់នៃព័ត៌មាននិងមាតិកាឌីជីថលដែលមិនអាចកាត់ផ្តាច់ឬញែកចេញពីគ្នាបាន និង ២)ភាពស៊ីសង្វាក់គ្នានៃតម្រូវការដំណោះស្រាយបញ្ហា ប្រសិទ្ធភាព សីលធម៌ ការទទួលខុសត្រូវ និងការជំរុញការចូលរួមរបស់ប្រជាពលរដ្ឋដោយប្រើប្រាស់ប្រព័ន្ធទាំងពីរនេះដំណាលគ្នាក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល។ អាស្រ័យហេតុនេះការរៀបចំក្របខណ្ឌសមត្ថភាព **អ.ឌ.ប.ព.** ជាការរួមបញ្ចូលនូវ **អ.ឌ.** និង **អ.ប.ព.** ជាមួយគ្នាដើម្បីបង្កើតនូវភាពគ្រប់ជ្រុងជ្រោយ សង្គតិភាព ឆ្លើយតបទៅនឹងការវិវត្តជាក់ស្តែងរបស់បច្ចេកវិទ្យា និងជួយសម្រួលដល់ការប្រើប្រាស់ក្របខណ្ឌនេះឱ្យមានប្រសិទ្ធភាពខ្ពស់។ បន្ថែមពីលើនិយមន័យ និងចង្អោមសមត្ថភាពតួអង្គពាក់ព័ន្ធក៏បានឯកភាពលើគោលការណ៍និងគុណតម្លៃនៃក្របខណ្ឌនេះដែរ។

## ២.៣. គោលការណ៍ និងគុណតម្លៃនៃក្របខណ្ឌសមត្ថភាព អ.ឌ.ប.ព.

**ក្របខណ្ឌសមត្ថភាព អ.ឌ.ប.ព. នេះត្រូវបានបង្កើត និងត្រូវអនុវត្តផ្អែកលើគោលការណ៍ដូចខាងក្រោម៖**

១. នីតិរដ្ឋ
២. បរិយាបន្ន
៣. រដ្ឋាភិបាលឌីជីថលនិងការចូលរួមរបស់ ប្រជាពលរដ្ឋ
៤. កិច្ចសហប្រតិបត្តិការឌីជីថល
៥. ការសិក្សាពេញមួយជីវិត
៦. កម្មសិទ្ធិបញ្ញា
៧. សេរីភាពនៃការបញ្ចេញមតិនិងការទទួលបាន ព័ត៌មាន

**ក្របខណ្ឌសមត្ថភាព អ.ឌ.ប.ព. នេះត្រូវបង្កើតឡើងផ្អែកលើគុណតម្លៃដូចខាងក្រោម៖**

១. សន្តិភាពនិងស្ថិរភាព
២. សមធម៌និងសមភាពយេនឌ័រ
៣. សេរីភាពនិងការទទួលខុសត្រូវ
៤. ពហុនិយមនិងភាពចម្រុះ
៥. ការគោរពនិងការយោគយល់
៦. ការយល់អារម្មណ៍
៧. សុចរិតភាព
៨. សុភវិនិច្ឆ័យ



# ៣. ក្របខណ្ឌសមត្ថភាព អ.ឌ.ប.ព. កម្ពុជា

ក្របខណ្ឌសមត្ថភាពអក្ខរកម្មឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន (**អ.ឌ.ប.ព.**) ត្រូវបានរៀបចំឡើងដោយផ្អែកលើគោលការណ៍ គុណតម្លៃ និងវិធីសាស្ត្ររៀបចំដូចរៀបរាប់ខាងលើ។ ជាលទ្ធផល និយមន័យ និងចង្កោមសមត្ថភាព ត្រូវបានកំណត់ដូចខាងក្រោម៖

## ៣.១. និយមន័យនៃអក្ខរកម្មឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន

**អក្ខរកម្មឌីជីថល (Digital Literacy)** គឺជាការចេះប្រើប្រាស់ឧបករណ៍ឌីជីថលប្រកបដោយភាពវិជ្ជមាន, ការទទួលខុសត្រូវ, ប្រសិទ្ធភាព, និងសុវត្ថិភាព ដើម្បីកំណត់, ឈ្វេងយល់, វាយតម្លៃ, បង្កើត, និងចែករំលែកមាតិកាឌីជីថល ព្រមទាំងការសិក្សាស្វែងយល់ពីរបៀបដែលប្រព័ន្ធឌីជីថលដំណើរការក្នុងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋប្រកបដោយបរិយាបន្ន។

**អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយនិងព័ត៌មាន (Media and Information Literacy)** គឺជាសំណុំសមត្ថភាពដែលផ្តល់សិទ្ធិអំណាចដល់ពលរដ្ឋក្នុងការឈ្វេងយល់អំពីមុខងារនៃប្រព័ន្ធផ្សព្វផ្សាយ និងអាក់សេស, ប្រើប្រាស់, ជ្រើសរើស, វាយតម្លៃ, រៀបចំ, ចែករំលែក, និងបង្កើតមាតិកាលើប្រព័ន្ធផ្សព្វផ្សាយ និងពីប្រភពព័ត៌មានផ្សេងៗប្រកបដោយការត្រិះរិះពិចារណា, ក្រមសីលធម៌, ប្រសិទ្ធភាព និងការទទួលខុសត្រូវ។

**ជារួម អក្ខរកម្មឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន** (**អ.ឌ.ប.ព.**) គឺជាសំណុំសមត្ថភាពក្នុងការប្រើប្រាស់ប្រព័ន្ធឌីជីថល និងការអាក់សេស, ប្រើប្រាស់, ជ្រើសរើស, វាយតម្លៃ, រៀបចំ, បង្កើត និងចែករំលែកមាតិកាព័ត៌មានលើប្រព័ន្ធទាំងនោះក្នុងកិច្ចការនិងការរស់នៅប្រចាំថ្ងៃ និងអាចប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយនិងព័ត៌មានពីប្រភពផ្សេងៗប្រកបដោយភាពវិជ្ជមាន, ការត្រិះរិះពិចារណា, ក្រមសីលធម៌, ប្រសិទ្ធភាព និងការទទួលខុសត្រូវ។

## ៣.២.ចង្កោមសមត្ថភាព អ.ឌ.ប.ព. កម្ពុជា

ចង្កោមសមត្ថភាព **អ.ឌ.ប.ព.** ត្រូវបានបែងចែកជា ៨ ដែលមានសមត្ថភាពសរុបចំនួន ១១៤ និងមាន ៣ កម្រិត គឺកម្រិតមូលដ្ឋាន កម្រិតមធ្យម និងកម្រិតខ្ពស់។ ចង្កោមសមត្ថភាព **អ.ឌ.ប.ព.** ត្រូវបានរៀបចំឡើងដោយមានមូលដ្ឋានលើការប្រៀបធៀបក្របខណ្ឌសមត្ថភាព **អ.ឌ.ប.ព.** ថ្នាក់តំបន់ និងសកលលោក និងការប្រជុំពិភាក្សា ការស្ទង់មតិ ការប្រឹក្សាយោបល់ និងសិក្ខាសាលាផ្ទៀងផ្ទាត់លទ្ធផលនិងផ្តល់យោបល់។ បញ្ជីចង្កោមសមត្ថភាពនេះ អាចនឹងត្រូវបានកែលម្អ ដោយផ្អែកលើការវាយតម្លៃ ដំណើរការកម្មវិធីបណ្តុះបណ្តាលលើកដំបូង ឬ ការរីកចម្រើននៅក្នុងប្រព័ន្ធបច្ចេកវិទ្យា ប្រព័ន្ធផ្សព្វផ្សាយឌីជីថល ការលេចឡើងនូវតម្រូវការនានា និងនិន្នាការសកល។

## ចង្កោមសមត្ថភាព អ.ឌ.ប.ព. ទាំង ៨



## តារាង២៖ បញ្ជីសំណុំសមត្ថភាពអក្ខរកម្មឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន (អ.ឌ.ប.ព.)

### ១). អក្ខរកម្មព័ត៌មាននិងទិន្នន័យ

**អក្ខរកម្មព័ត៌មាននិងទិន្នន័យ** គឺជាសមត្ថភាពក្នុងការស្វែងរក, វាយតម្លៃ, ប្រើប្រាស់, និងចែករំលែកព័ត៌មាន និងទិន្នន័យប្រកបដោយប្រសិទ្ធភាពនៅក្នុងពិភពឌីជីថល។ សមត្ថភាពនេះរួមបញ្ចូលជំនាញដូចជាការគិតត្រិះរិះពិចារណា, ការសិក្សាស្រាវជ្រាវ, ការវាយតម្លៃប្រភព, ការវិភាគទិន្នន័យ, និងការចែករំលែកព័ត៌មានប្រកបដោយការទទួលខុសត្រូវ។

ក្នុងចង្កោមសមត្ថភាពអក្ខរកម្មព័ត៌មាននិងទិន្នន័យ មានសមត្ថភាព ដូចខាងក្រោម៖

| កម្រិតមូលដ្ឋាន | កម្រិតមធ្យម | កម្រិតខ្ពស់ |
|---|---|---|
| • ចេះបញ្ជាក់ប្រាប់អំពីព័ត៌មានដែលត្រូវការ<br>Articulate information needs<br>• ចេះស្វែងរក ស្រាវជ្រាវ និងច្រោះព័ត៌មាននិងមាតិកាឌីជីថល<br>Browse, search, and filter information and digital content<br>• យល់អំពីរបៀបក្នុងការទទួលបានព័ត៌មានពីប្រភពដែលសមស្រប, ត្រឹមត្រូវ និងអាចជឿទុកចិត្តបាន<br>Know how to access information from appropriate, accurate, credible information sources<br>• ចេះរៀបចំ,រក្សាទុក,និងទាញយកទិន្នន័យពីកន្លែងផ្ទុកទិន្នន័យ ដូចជា អង្គផ្ទុកទិន្នន័យ, កន្លែងផ្ទុកទិន្នន័យលើក្លោដ និងកន្លែងផ្ទុកទិន្នន័យឌីជីថលផ្សេងៗទៀត | • ចេះរៀបចំទិន្នន័យទៅតាមប្រធានបទ ឬ តាមលំនាំ (ឧទាហរណ៍ រៀបតាមកាលវេលា, ហេតុនិងផល, បញ្ហានិងដំណោះស្រាយ ។ល។)<br>Organize data according to themes or patterns (e.g., chronological, cause-effect, problem solution, etc.)<br>• យល់ច្បាស់អំពីកត្តាជំរុញ ឬ ផលប្រយោជន៍របស់បុគ្គល ឬ ស្ថាប័នដែលផលិតមាតិកា<br>Decipher the motivations or interests of individuals or organizations producing content<br>• ចេះរៀបចំឯកសារយោង ដោយប្រើប្រាស់ឧបករណ៍ឌីជីថលជាជំនួយ (ឧទាហរណ៍ Zotero, Mendeley, Endnote,...) ដើម្បីប្រមូល, រៀបចំ និងដាក់កំណត់យោងទៅប្រភពឯកសារ | • ចេះបែងចែកប្រភេទផ្សេងៗនៃព័ត៌មានច្របូកច្របល់ ហើយដឹងអំពីរបៀបដែលព័ត៌មានទាំងនេះបន្តកើតឡើងមិនចេះចប់នៅលើប្រព័ន្ធផ្សព្វផ្សាយ<br>Distinguish the different types of information disorder and how these are perpetuated in media<br>• ចេះទាមទារឱ្យក្រុមហ៊ុនបច្ចេកវិទ្យាធំៗមានគណនេយ្យភាពនិងតម្លាភាពចំពោះ ការប្រើប្រាស់ដានជើងទិន្នន័យរបស់ខ្លួន (data footprints)<br>Demand accountability and transparency from big technology companies about how one's data footprints are used<br>• ចេះកំណត់ភាពខុសគ្នារវាងព័ត៌មានសាធារណៈ និងព័ត៌មានជាប់កម្មសិទ្ធិ (សិទ្ធិអ្នកនិពន្ធ, ពាណិជ្ជសញ្ញា) |

| កម្រិតមូលដ្ឋាន | កម្រិតមធ្យម | កម្រិតខ្ពស់ |
|---|---|---|
| Organize, save, and retrieve data from hard drives, cloud storage, and other digital repositories<br>• ដឹងអំពីច្បាប់ជាតិពាក់ព័ន្ធនឹងទាញយកព័ត៌មានមកប្រើប្រាស់ពីប្រភពផ្សេងៗ, ការផលិតព័ត៌មាន និង ការផ្សព្វផ្សាយព័ត៌មាន (ឧទាហរណ៍ ការទទួលបានព័ត៌មាន, ឯកជនភាព, សិទ្ធិអ្នកនិពន្ធ) ព្រមទាំងស្តង់ដាអន្តរជាតិពាក់ព័ន្ធនឹងច្បាប់ទាំងនេះ<br>Know national laws related to information sourcing, production, and dissemination (e.g., access to information, privacy, copyright) and international standards related to these laws<br>• ចេះសំអាងសិទ្ធិទទួលបានព័ត៌មាន<br>Invoke right to information<br>• ចេះសម្គាល់ការបោកបញ្ឆោត និង តំណភ្ជាប់ឆបោកតាមរយៈ ការផ្ញើសារ SMS ឬ អ៊ីម៉ែល<br>Detect scams, phishing sent through mobile SMS or emails<br>• ចេះផ្ទៀងផ្ទាត់ខ្លឹមសារដោយពឹងលើប្រភពដែលអាចជឿទុកចិត្តបាន ដើម្បីប្រយុទ្ធប្រឆាំងនឹងព័ត៌មានមិនពិត<br>Cross-check content through credible sources to help fight disinformation | Manage references used using digital tools (e.g., Zotero, Mendeley, Endnote, etc) to collect, organize, cite sources<br>• យល់អំពីគោលការណ៍មួយចំនួនដូចជា៖<br>∘ ការប្រមូលទិន្នន័យអប្បបរមា<br>∘ ការប្រមូលនិងប្រើប្រាស់ទិន្នន័យតាមគោលដៅដែលបានកំណត់<br>∘ ការកំណត់រយៈពេល រក្សាទុកទិន្នន័យ<br>∘ សុក្រឹតភាពនៃទិន្នន័យ, តម្លាភាព, និងគោលការណ៍ផ្សេងទៀតនៃកិច្ចការពារទិន្នន័យបុគ្គល។<br>Understand principles such as:<br>∘ Data minimization<br>∘ Purpose limitation<br>∘ Storage limitation<br>∘ Accuracy, transparency, and other principles of data protection<br>• ចេះបកស្រាយពីរូបតាងទិន្នន័យ និងទិន្នន័យឌីជីថលផ្សេងៗទៀត<br>Interpret visualizations and other digital data<br>• ចេះប្រើប្រាស់និងស្រាវជ្រាវលើកាតាឡុកបណ្ណាល័យអនឡាញ<br>Navigate the Online Public Access Catalog (OPAC) | Distinguish between public domain information and proprietary information (copyright, trademarks)<br>• ចេះវិភាគទិន្នន័យដោយប្រើប្រាស់កម្មវិធីស្ថិតិនានា ដូចជា SPSS, NVivo, QDA Miner<br>Analyze data using software (e.g., SPSS, NVivo, QDA Miner, etc.)<br>• ចេះប្រើប្រាស់បច្ចេកទេស និង ឧបករណ៍ផ្ទៀងផ្ទាត់ព័ត៌មាន<br>Apply fact-checking tools and techniques<br>• ចេះតាមដាននិងវិភាគពីរបៀបដែលទស្សនិកជន ឆ្លើយតបទៅនឹងព័ត៌មានដែលទទួលបាន ព្រមទាំងផលប៉ះពាល់នានា<br>Monitor and analyze how audiences respond to information received and the effects/impact |

## ២). ប្រតិបត្តិការឧបករណ៍ឌីជីថលនិងសុសវែរ

**ប្រតិបត្តិការឧបករណ៍ឌីជីថលនិងសុសវែរ** គឺជាសមត្ថភាពក្នុងការប្រើប្រាស់ឧបករណ៍ឌីជីថលនិងសុសវែរ ដើម្បីដំណើរការនិងគ្រប់គ្រងប្រព័ន្ធឌីជីថល ជាពិសេសចំណេះដឹងក្នុងការអភិវឌ្ឍបច្ចេកវិទ្យាទំនើបៗចុងក្រោយ ដូចជា បញ្ញាសិប្បនិម្មិត ប្លុកឆេន។ល។

**ក្នុងចង្កោមសមត្ថភាពប្រតិបត្តិការឧបករណ៍ឌីជីថលនិងសុសវែរ មានសមត្ថភាព ដូចខាងក្រោម៖**

| កម្រិតមូលដ្ឋាន | កម្រិតមធ្យម | កម្រិតខ្ពស់ |
|---|---|---|
| • ចេះកំណត់មុខងារនិងប្រើប្រាស់ឧបករណ៍ឌីជីថល និងបច្ចេកវិទ្យានានា<br><br>Identify and use the functions of hardware tools and technologies<br><br>• ដឹងអំពីព័ត៌មាននិងមាតិកាឌីជីថលដែលចាំបាច់ ដើម្បីប្រតិបត្តិការសុសវែរនិងឧបករណ៍ឌីជីថល<br><br>Know the information and digital content that are necessary to operate software and hardware<br><br>• ចេះប្រើប្រាស់កម្មវិធីជួបប្រជុំអនឡាញ (Zoom, MS Team, Google Meet ។ល។)<br><br>Know how to use videoconferencing platforms (Zoom, MS Team, Google Meet, etc.) | • ចេះដំឡើងកម្មវិធីកុំព្យូទ័រផ្សេងៗតាមតម្រូវការ<br><br>Know how to install software<br><br>• ចេះពីរបៀបដោះស្រាយបញ្ហាបច្ចេកទេសលើប្រព័ន្ធផ្សព្វផ្សាយឌីជីថល<br><br>Know where or how to troubleshoot technical problems in using digital media.<br><br>• យល់អំពីមូលដ្ឋាននៃការសរសេរកូដ<br><br>Learn how to do coding<br><br>• ស្គាល់សញ្ញាដែលបង្ហាញថាឧបករណ៍ឌីជីថលបានឆ្លងមេរោគកុំព្យូទ័រ និងចេះចាត់វិធានការជាមូលដ្ឋានក្នុងការឆ្លើយតប<br><br>Know indications that a digital device is infected with a computer virus and know basic troubleshooting interventions | • ចេះបង្កើតកម្មវិធីវេបឬកម្មវិធីទូរសព្ទ<br><br>Create mobile/web apps<br><br>• ចេះសរសេរកម្មវិធីដោយប្រើប្រាស់ឧបករណ៍នានាពីប្រភពកូដចំហ (open-source tools)<br><br>Do programming using open-source tools<br><br>• ចេះអភិវឌ្ឍបច្ចេកវិទ្យាទំនើបៗចុងក្រោយ (បញ្ញាសិប្បនិម្មិត, រ៉ូបូត,បច្ចេកវិទ្យាក្លោដ, បច្ចេកវិទ្យាតថភាពនិម្មិត (VR),បច្ចេកវិទ្យាតថភាពបន្ថែម (AR), ប្លុកឆេន, អ៊ីនធឺណិតនៃវត្ថុ, ទិន្នន័យធំ)<br><br>Develop frontier technologies (AI, Robotic, Cloud, VR, AR, Blockchain, IoT, Big Data, ...) |

| កម្រិតមូលដ្ឋាន | កម្រិតមធ្យម | កម្រិតខ្ពស់ |
|---|---|---|
| • ចេះប្រើប្រាស់កម្មវិធីឌីជីថលក្នុងការធ្វើប្រតិបត្តិការ (ឧទាហរណ៍ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ការកក់សេវាតាមអនឡាញ)<br>Use digital solutions for transactions (e.g., e-commerce, online booking, etc.) | • យល់ដឹងអំពីនិងចូលរួមក្នុងឧស្សាហកម្ម ៤.0 ដោយប្រើប្រាស់បច្ចេកវិទ្យាចុងក្រោយ (បញ្ញាសិប្បនិម្មិត, រ៉ូបូត, បច្ចេកវិទ្យាក្លោដ, បច្ចេកវិទ្យាតថភាពនិម្មិត (VR), បច្ចេកវិទ្យាតថភាពបន្ថែម (AR), ប្លុកឆេន, អ៊ីនធឺណិតនៃវត្ថុ, ទិន្នន័យធំ)<br>Understand and participate in Industry ៤.0 using frontier technologies (AI, Robotic, Cloud, VR, AR, Blockchain, IoT, Big Data, ...) | |

### ៣). អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ

**អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ** គឺជាសមត្ថភាពក្នុងការយល់ដឹងនិងវិភាគសាររបស់ប្រព័ន្ធផ្សព្វផ្សាយ។ សមត្ថភាពនេះចាំបាច់សម្រាប់ប្រជាពលរដ្ឋក្នុងការទទួលព័ត៌មាននិងការចូលរួមនៅក្នុងសង្គមប្រជាធិបតេយ្យ។ ចំណេះដឹងផ្នែកប្រព័ន្ធផ្សព្វផ្សាយរួមមានការយល់ដឹងអំពីតួនាទីនៃប្រព័ន្ធផ្សព្វផ្សាយនៅក្នុងសង្គម, ការវាយតម្លៃខ្លឹមសារប្រព័ន្ធផ្សព្វផ្សាយ, និងការផលិតនិងការចែករំលែកបទអត្ថាធិប្បាយដើម្បីឆ្លើយតបត្រឡប់វិញ។

## ក្នុងចង្កោមសមត្ថភាពអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ មានសមត្ថភាព ដូចខាងក្រោម៖

| កម្រិតមូលដ្ឋាន | កម្រិតមធ្យម | កម្រិតខ្ពស់ |
|---|---|---|
| • យល់អំពីតួនាទីដ៏មានសារៈសំខាន់នៃប្រព័ន្ធផ្សព្វផ្សាយក្នុងការលើកកម្ពស់ការចូលរួមតាមបែបប្រជាធិបតេយ្យ (ដូចជា បដិគុល្យការ, តម្លាភាព, វេទិកាបញ្ចេញមតិរបស់ពលរដ្ឋ)<br>Understand the important role of media in promoting and preserving democratic discourse (e.g., checks and balances, transparency, platform for people's self-expression<br><br>• យល់អំពីសិទ្ធិបុគ្គលដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ (ដូចជា សិទ្ធិបញ្ចេញមតិ, សិទ្ធិខាងជំនឿសាសនា, សិទ្ធិប្រមូលផ្តុំ, សិទ្ធិទទួលព័ត៌មាន)<br>Know constitutionally enshrined individual freedoms (e.g., speech, religion, association, information)<br><br>• ចេះបើកចិត្តឱ្យទូលាយ គោរព និងទទួលយកភាពខុសគ្នារវាងក្រុមផ្សេងៗគ្នា(វប្បធម៌,សាសនា, ភេទ, ស្ថានភាពសង្គមសេដ្ឋកិច្ច)<br>Practice openness; respect and tolerance for differences among diverse groups/sectors (culture, religion, gender, socioeconomic class) | • យល់ថាអ្នកសារព័ត៌មានត្រូវទទួលការបណ្តុះបណ្តាលប្រកបដោយវិជ្ជាជីវៈ ដើម្បីរាយការណ៍ព័ត៌មាន ដែលមានភាពត្រឹមត្រូវផ្អែកលើការពិត និងមិនលម្អៀង<br>Recognize that journalists are professionally trained to report news that is expectedly accurate, factual, objective, and balanced<br><br>• យល់ថាខ្លឹមសារប្រព័ន្ធផ្សព្វផ្សាយអាចទទួលរងឥទ្ធិពលពីកត្តាផ្សេងៗ ដូចជា នយោបាយ, ពាណិកម្ម, សេដ្ឋកិច្ច, សង្គម។ល។<br>Understand that media content is influenced by an interplay of political, commercial, and social factors<br><br>• យល់អំពីសិទ្ធិមនុស្សអន្តរជាតិ ជាពិសេស សេរីភាពក្នុងការបញ្ចេញមតិ និងការទទួលព័ត៌មាន និងទំនាក់ទំនងនៃសិទ្ធិទាំងនេះ ក្នុងការជំរុញ  ការចូលរួមរបស់ប្រជាពលរដ្ឋ<br>Understand the International Human Rights especially the freedoms of expression and information and how these relate to healthy civic participation<br><br>• យល់អំពីរបៀបស្នើសុំឱ្យ ប្រព័ន្ធផ្សព្វផ្សាយពន្យល់ពី ការបំពានពាក់ព័ន្ធនឹងការប្រើពាក្យស្អប់ខ្ពើម រើសអើង និងជ្រុលនិយម | • ចេះវាយតម្លៃមាតិកាព័ត៌មានបានយ៉ាងល្អិតល្អន់ ដោយពិនិត្យទៅលើភាពត្រឹមត្រូវ, ភាពរសើបរបស់មាតិកានោះ (ឧទាហរណ៍ វប្បធម៌ និងសាសនា), ការច្នៃប្រឌិត, និងគុណភាពបច្ចេកទេស (ឧទាហរណ៍ គុណភាពនៃការសរសេរ, ការកែសម្រួល, ការរចនា, ការផលិត) ។ល។<br>Evaluate critically media content by assessing its accuracy, sensitivity (e.g., culture and religion), creativity, technical quality (e.g., quality of writing, editing, design, production) etc.<br><br>• ចេះកំណត់ដឹងពីផ្នត់គំនិតបុរេនិច្ឆ័យរបស់ប្រព័ន្ធផ្សព្វផ្សាយនៅក្នុងការឆ្លុះបញ្ចាំងទិដ្ឋភាពជាក់ស្តែងណាមួយ និងដឹងពីវិធីដោះស្រាយបញ្ហាទាំងនេះ<br>Detect media's stereotypes/ prejudices in its portrayals of reality to inform actions that will address these stereotypes |

## ក្នុងចង្កោមសមត្ថភាពអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ មានសមត្ថភាព ដូចខាងក្រោម៖

| កម្រិតមូលដ្ឋាន | កម្រិតមធ្យម | កម្រិតខ្ពស់ |
|---|---|---|
| • ចេះកំណត់ដឹងថាប្រភពព័ត៌មានណាអាចជឿទុកចិត្តបាន<br><br>Identify the trustworthiness and credibility of media sources | Learn how to call out media outlets' violations pertaining to hate speech, intolerance, radicalism, and extremism<br><br>• យល់អំពីរបៀបក្នុងការជួយដល់សហគមន៍ ដែលមិនទទួលបានសេវាឬមិនមានលទ្ធភាពចូលប្រើប្រាស់ ប្រព័ន្ធផ្សព្វផ្សាយ<br>Develop sensitivity to help unserved and underserved communities/sectors that have limited or zero media access<br><br>• យល់អំពីរបៀបធ្វើសារព័ត៌មានប្រជាពលរដ្ឋ<br>Engage in citizen journalism<br><br>• ចេះវាយតម្លៃថាជារូបភាព/វីដេអូដើម ឬជារូបភាព/វីដេអូត្រូវបានកែច្នៃ និងក្លែងក្លាយ (រួមបញ្ចូលទាំងវីដេអូក្លែងដោយប្រើបញ្ញាសិប្បនិម្មិត)<br>Assess the authenticity of photos, videos ( including deep fakes )<br><br>• យល់អំពីប្រភេទនៃការដាក់កំហិតមាតិកាព័ត៌មាន<br>Discern types of censoring news content<br><br>• យល់អំពីច្បាប់ជាតិពាក់ព័ន្ធនឹងប្រព័ន្ធផ្សព្វផ្សាយ, អ៊ីនធឺណិត និងទូរគមនាគមន៍ និងអនុលោមភាពរបស់ច្បាប់ទាំងនេះជាមួយនឹងស្តង់ដាអន្តរជាតិ<br>Know Cambodia laws pertaining to media, internet, and telecommunications and their compliance with international standards | • ចេះផលិតនិងចែករំលែកបទអត្ថាធិប្បាយដើម្បីបកស្រាយ និងផ្តល់ជម្រើសជ្រុងផ្សេងនៃព័ត៌មាន (ពាក់ព័ន្ធនឹងសន្តិភាព, បរិយាបន្ន, សមភាព, ការសន្ទនាអន្តរវប្បធម៌)<br><br>Produce and share counter and alternative media narratives ( of peace, inclusion, equality, and intercultural dialogue )<br><br>• យល់អំពីដំណើរការនៃអាល់ហ្គោរីតនិងឥទ្ធិពលរបស់វាទៅលើប្រភពនិងការផ្សព្វផ្សាយព័ត៌មាន រួមទាំង អ្នកបន្ទរព័ត៌មាន<br><br>Know how algorithm works and its impact on news dissemination and sourcing including echo chambers |

### ៤). ការប្រាស្រ័យទាក់ទងនិងកិច្ចសហប្រតិបត្តិការ

**ការប្រាស្រ័យទាក់ទងនិងកិច្ចសហប្រតិបត្តិការ** គឺជាសមត្ថភាពក្នុងការទំនាក់ទំនង និងបង្កើតកិច្ចសហប្រតិបត្តិការការងារតាមប្រព័ន្ធអនឡាញប្រកបដោយប្រសិទ្ធភាពនិងក្រមសីលធម៌ ស្របតាមលក្ខខណ្ឌនៃការប្រើប្រាស់ប្រព័ន្ធឌីជីថល និងជំរុញការផ្តល់យោបល់ផ្សេងៗពីអ្នកដទៃក្នុងបរិស្ថានឌីជីថល។

## ក្នុងចង្កោមសមត្ថភាពការប្រាស្រ័យទាក់ទងនិងកិច្ចសហប្រតិបត្តិការមានសមត្ថភាពដូចខាងក្រោម៖

| កម្រិតមូលដ្ឋាន | កម្រិតមធ្យម | កម្រិតខ្ពស់ |
|---|---|---|
| • ចេះអាន យល់ព្រម និងឯកភាពលើលក្ខខណ្ឌនៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ឌីជីថល ជាពិសេសបណ្តាញផ្សព្វផ្សាយសង្គម<br>Read and consent to the terms and conditions of Community Standards in using digital media, especially social media<br>• អនុវត្តតាមក្រមសីលធម៌និងសេរីភាពបញ្ចេញមតិក្នុងកិច្ចពិភាក្សា<br>Follow code of ethics and freedom of expression during discussions<br>• ចេះធ្វើការងាររួមជាមួយអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយឌីជីថល ដែលមកពីមជ្ឈដ្ឋានចម្រុះនិងមានអត្តសញ្ញាណផ្សេងៗគ្នា<br>Work with people/digital media users from diverse backgrounds and identities | • ចេះភ្ជាប់ទំនាក់ទំនងជាមួយអ្នកប្រើប្រាស់ផ្សេងៗទៀត តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ឌីជីថលដែលសមស្រប (ឧទាហរណ៍ បណ្តាញផ្សព្វផ្សាយសង្គម, កម្មវិធីផ្ញើសារ, បច្ចេកវិទ្យាអប់រំនានា ។ល។) ដើម្បីចែករំលែកមាតិកា, ចូលចំណោម និងចែករំលែកគំនិតនិងយោបល់<br>Interact with other users through appropriate digital media (e.g., social media, messaging apps, education technologies, etc.) to share content, socialize, exchange ideas and opinions.<br>• ចេះធ្វើការរួមគ្នាដោយប្រើប្រាស់ថ្នាលឌីជីថលរួមដើម្បីបង្កើតមាតិកា (ឧទាហរណ៍ Google Drive, One Drive, Stormboard ។ល។)<br>Work with others using collaborative digital tools (e.g., Google Drive, One Drive, Stormboard, etc.) to create content. | • ចេះសំយោគទស្សនៈរួមចេញពីគំនិតផ្ទុយគ្នា ដើម្បីជំរុញសាមគ្គីភាព ការគោរពភាពខុសគ្នា និងប្រយោជន៍សង្គម<br>Find common grounds among opposing ideas to promote unity, respect for diversity, and social goods<br>• ចេះបង្កើតកម្មវិធីតាមប្រព័ន្ធអនឡាញដើម្បីដោះស្រាយបញ្ហាសង្គម ជាអាទិ៍តាមរយៈការរៃអង្គាសថវិកាជួយអ្នកខ្វះខាត<br>Launch online advocacies to address social issues, including crowdfunding to help the needy<br>• ចេះគ្រប់គ្រងការសន្ទនាដែលមានលក្ខណៈបំពុលសង្គមលើប្រព័ន្ធអនឡាញ រួមទាំងការដោះស្រាយជាមួយការបង្ហោះលេងសើច<br>Manage toxic conversations online including dealing with trolls |

| កម្រិតមូលដ្ឋាន | កម្រិតមធ្យម | កម្រិតខ្ពស់ |
|---|---|---|
| • ធ្វើការដោយស្មើភាពជាមួយអ្នករួមការងារក្នុងលំហឌីជីថល<br>Treat co-workers in shared digital spaces as co-equals<br>• គោរពតាមស្មារតីនៃការរក្សាសិទ្ធិបែបស៊ីស៊ី ( creative commons - cc )<br>Observe the ethics of creative commons<br>• យល់អំពីសិទ្ធិអ្នកប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ក្នុងការទទួលយក បដិសេធ ឬ កែតម្រូវខ្លឹមសារ ទៅតាមតម្រូវការនិងផលប្រយោជន៍របស់ខ្លួន<br>Recognize that the users/ audience of digital technologies have the power to accept, reject, or adjust content according to their own interests and needs.<br>• ចេះកំណត់និងលេងហ្គេមអនឡាញដែលសមស្របតាមអាយុ ( ឧទាហរណ៍ ប្រធានបទ, មូលបទ, ភាសា, រូបភាព )<br>Identify and play age-appropriate online games ( i.e., topics, themes, language, visuals ) | • ចេះផ្ដល់មតិកែលម្អប្រកប ដោយភាពវិជ្ជមាន<br>Practice healthy feedback<br>• ចេះចូលរួមក្នុងក្រុមជជែកពិភាក្សាតាមចំណង់ចំណូលចិត្តនិងតាមកម្មវិធីផ្ដល់ការប្រឹក្សា<br>Join chat groups for special interests and mentoring programs<br>• ចេះគោរពសិទ្ធិរបស់អ្នកប្រើប្រាស់ផ្សេងទៀតក្នុងការរក្សាអនាមិកភាពលើប្រព័ន្ធអនឡាញ<br>Respect rights of other online users to be anonymous<br>• ចេះបង្ហាញជំនាញទន់ក្នុងការលេងហ្គេមអនឡាញរួមគ្នា<br>Exhibit social skills in collaborative online games<br>• ចេះចូលរួមក្នុងក្រុមពិសេសដើម្បីបង្កើនផលប្រយោជន៍<br>Join special groups to boost interests ( e.g., advocacy, productivity )<br>• ចេះគោរពការសម្ងាត់របស់អ្នកប្រើប្រាស់<br>Respect user confidentiality | • ចេះប្រើវិធីសាស្ត្រហ្គេមសម្រាប់ជំរុញការចូលរួម និងលើកទឹកចិត្តឱ្យមានភាពស្វាហាប់ជាក្រុមដើម្បីបញ្ចេញភាពច្នៃប្រឌិត និងការប្រកួតប្រជែង តាមរយៈការប្រើប្រាស់ឧបករណ៍ឌីជីថល<br>Gamify group dynamics to practice creativity and healthy competition while using digital tools<br>• ចេះសម្របខ្លួនទៅតាមប្រភេទអ្នកប្រើប្រាស់ និងប្រព័ន្ធផ្សព្វផ្សាយឌីជីថល<br>Adapt to various types of audience and digital media |

### ៥). ការបង្កើតមាតិកាឌីជីថល

ការបង្កើតមាតិកាឌីជីថល គឺជាសមត្ថភាពក្នុងការបង្កើត និងចែករំលែកមាតិកាឌីជីថលប្រកបដោយក្រមសីលធម៌និងការទទួលខុសត្រូវ ដូចជាការគោរពកម្មសិទ្ធិបញ្ញា និងការយល់ដឹងអំពីការប្រើប្រាស់អាជ្ញាបណ្ណច្នៃប្រឌិតផ្សេងៗ។

## ក្នុងចង្កោមសមត្ថភាពការបង្កើតមាតិកាឌីជីថល មានសមត្ថភាព ដូចខាងក្រោម៖

| កម្រិតមូលដ្ឋាន | កម្រិតមធ្យម | កម្រិតខ្ពស់ |
|---|---|---|
| • ចេះបញ្ជាក់ប្រភពព័ត៌មាន ឬខ្លឹមសារដើម ដើម្បីផ្តល់ការគោរពលើកម្មសិទ្ធិបញ្ញារបស់អ្នកនិពន្ធ<br><br>Acknowledge sources to respect the original authors, the resources they invested to create the content, and their intellectual property rights<br><br>• យល់ដឹងថាមាតិកាឌីជីថលមួយចំនួន (ឧទាហរណ៍ រូបថត តន្ត្រី) មានជាប់កម្មសិទ្ធិបញ្ញា និងត្រូវស្នើសុំអាជ្ញាបណ្ណមុននឹងអាចយកទៅប្រើប្រាស់<br><br>Understand that some digital content (e.g., photo, music) have copyrights and licenses before these can be used.<br><br>• ចេះគោរពព័ត៌មានដែលជាប់កម្មសិទ្ធិ (សិទ្ធិអ្នកនិពន្ធ, ពាណិជ្ជសញ្ញា)<br><br>Respect proprietary information (copyright, trademarks) | • ចេះបង្កើតមាតិកាក្នុងទម្រង់ផ្សេងៗ (ឧទាហរណ៍រូបថតវីដេអូអត្ថបទ) ដោយប្រើឧបករណ៍និងកម្មវិធីឌីជីថលផ្សេងៗ<br><br>Create content in different formats (e.g., photo, video, text) using different digital media tools and applications<br><br>• ចេះកែសម្រួល ឬផ្តល់មតិយោបល់លើមាតិកាដែលបង្កើតឡើងដោយអ្នកដទៃ ដើម្បីកែលម្អមាតិកា ឬ បង្កើតមាតិកាថ្មីមួយទៀត<br><br>Edit or give comments on content created by other users to improve the content or create a new one<br><br>• យល់ដឹងថាមាតិកាទាំងអស់ដែលបានបង្ហោះនៅលើប្រព័ន្ធផ្សព្វផ្សាយឌីជីថល ជាពិសេសបណ្តាញផ្សព្វផ្សាយសង្គម គឺជាផ្នែកមួយនៃដានជើងឌីជីថល ដែលផ្សារភ្ជាប់នឹងអ្នកបង្កើតមាតិកា | • ចេះឈ្វេងយល់ពីមេតាវើសជាកន្លែងសម្រាប់បង្កើតមាតិកា និងការចូលរួមរបស់ទស្សនិកជន<br><br>Understand metaverse as a space for content creation and audience engagement<br><br>• ចេះបែងចែកនិងកំណត់ដឹងមាតិកាឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលកើតឡើងក្នុងបរិបទនៃជម្លោះប្រដាប់អាវុធ ដូចដែលមានចែងក្នុងមាត្រា ៨(២) នៃ លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ<br><br>Discern whether social media content promotes international war crimes such as torture and cruel, inhumane, or degrading punishment, aggression, crimes against humanity and war crimes which occur in the context of an armed conflict as specified in Article 8(2) of the Rome Statute of the International Criminal Court |

| កម្រិតមូលដ្ឋាន | កម្រិតមធ្យម | កម្រិតខ្ពស់ |
|---|---|---|
| • ចេះបែងចែកមាតិកាណាដែលអាចចែករំលែកជាសាធារណៈ មាតិកាណាត្រូវរក្សាទុកជាឯកជន និងមាតិកាណាអាចចែករំលែកតែជាមួយអាជ្ញាធរពាក់ព័ន្ធ<br>Distinguish what content can be made public, private, and only shared with authorities<br>• យល់ដឹងពីការប្រើប្រាស់ដោយស្មើភាពនៃឯកសារឌីជីថលដែលមានការរក្សាសិទ្ធិអ្នកនិពន្ធ<br>Understand fair use of digital copyrighted materials<br>• ចេះបង្កើតនិងបង្ហោះមាតិកាតាមបណ្តាញផ្សព្វផ្សាយសង្គមដែលមិនមានអត្ថន័យបង្កគ្រោះថ្នាក់ (ឧទាហរណ៍ ប្រើពាក្យប្រមាថ ការញុះញង់ ស្អប់ខ្ពើម បំភាន់ បំភ្លៃបំផ្លើស រើសអើងជាតិសាសន៍ ការស្តីបន្ទោសជនរងគ្រោះ អំពើហិង្សា ។ល។)<br>Create social media posts that do not contain harmful content (e.g., hate speech, sexism, intolerance, racism, discrimination, victim-blaming, violence, etc.) | Understand that all content posted on digital media, especially social media, becomes part of digital footprints traceable to content creators | |

| កម្រិតមូលដ្ឋាន | កម្រិតមធ្យម | កម្រិតខ្ពស់ |
|---|---|---|
| • ចេះឈ្វេងយល់ពីសាវតាររបស់ទស្សនិកជនតាមប្រព័ន្ធអនឡាញ ដើម្បីយកជាមូលដ្ឋាននៃការបង្កើតមាតិកា<br><br>Understand the background of online audiences as one basis of content creation<br><br>• ចេះបង្ហោះមាតិកាដែលគោរពឯកជនភាព ភាពអនាមិក និងការសម្ងាត់<br><br>Upload content that respects the subjects' rights to privacy, anonymity, confidentiality | | |

## ៦). សន្តិសុខនិងសុវត្ថិភាព

**សន្តិសុខនិងសុវត្ថិភាព** គឺជាសមត្ថភាពដែលបុគ្គលម្នាក់ៗអាចចូលរួមយ៉ាងសកម្មក្នុងការរៀបចំបរិស្ថានឌីជីថលប្រកបដោយសុវត្ថិភាពនិងការទទួលខុសត្រូវ។ តាមរយៈសមត្ថភាពទាំងនេះ បុគ្គលម្នាក់ៗអាចចូលប្រើប្រព័ន្ធអនឡាញប្រកបដោយទំនុកចិត្ត អាចការពារខ្លួននិងអ្នកដទៃពីគ្រោះថ្នាក់នានា និងចូលរួមចំណែកក្នុងការបង្កើតនូវបទពិសោធន៍ឌីជីថលប្រកបដោយភាពវិជ្ជមាននិងបរិយាបន្នសម្រាប់មនុស្សគ្រប់គ្នា។

ក្នុងចង្កោមសមត្ថភាពសន្តិសុខនិងសុវត្ថិភាព មានសមត្ថភាព ដូចខាងក្រោម៖

| ក្រមិតមូលដ្ឋាន | ក្រមិតមធ្យម | ក្រមិតខ្ពស់ |
|---|---|---|
| • ចេះគ្រប់គ្រងគណនីបណ្តាញផ្សព្វផ្សាយសង្គមឱ្យមានសុវត្ថិភាព និងដឹងពីអន្តរាគមន៍ជាមូលដ្ឋាន ក្នុងករណីមានការលួចចូលប្រើប្រាស់គណនី<br>Know how to manage a secure social media account, including basic interventions in case of hacking<br>• យល់ដឹងពីហានិភ័យនៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយឌីជីថល<br>Understand the risks of using digital media<br>• យល់ដឹងពីរបៀបដែល ក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយឌីជីថលប្រមូល និងការពារព័ត៌មានផ្ទាល់ខ្លួន និងព័ត៌មានរសើបរបស់អ្នកប្រើប្រាស់<br>Understand how digital media companies collect and protect personal and sensitive information<br>• ចេះរាយការណ៍អំពីអ្នកបំពានស្តង់ដាសហគមន៍នៃបណ្តាញផ្សព្វផ្សាយសង្គម ដើម្បីបង្កើតបរិយាកាសប្រព័ន្ធផ្សព្វផ្សាយឌីជីថលដែលមានសុវត្ថិភាព<br>Report violators of community standards of social media to create a safe and nurturing digital media environment<br>• ចេះសំអាងសិទ្ធិទាមទារឱ្យលុបព័ត៌មានខ្លួនចេញពីថ្នាលឌីជីថល<br>Invoke right to erasure/ be forgotten | • ចេះប្រើប្រាស់សមត្ថភាពក្នុងការឈ្វេងយល់ ឆ្លើយតប និងគ្រប់គ្រងអារម្មណ៍ក្នុងពិភពឌីជីថល (ឧទាហរណ៍ កាត់បន្ថយហានិភ័យចំពោះសុខុមាលភាពផ្លូវកាយ និងផ្លូវចិត្ត) តាមរយៈការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយឌីជីថលដែលមានការត្រួតពិនិត្យត្រឹមត្រូវ<br>Practice digital emotional intelligence (e.g., reduce the risks to physical and mental wellbeing) through regulated use of digital media<br>• កំណត់ដឹងនិងកត់សម្គាល់មាតិកាតាមបណ្តាញផ្សព្វផ្សាយសង្គម ដែលបង្កគ្រោះថ្នាក់ដល់សុខុមាលភាពនៃជនងាយរងគ្រោះ (ឧទាហរណ៍ កុមារ ក្មេងជំទង់ មនុស្សចាស់ ជនពិការ ជនជាតិដើមភាគតិច ។ល។)<br>Understand and flag social media content that endangers the social wellbeing of vulnerable sectors (e.g., children, teens, older adults, persons with disabilities, indigenous people, etc.)<br>• ចេះរាយការណ៍អំពីការរំលោភលើឯកជនភាពទិន្នន័យ និងសុវត្ថិភាពទិន្នន័យ<br>Know how to report breach of data privacy and security<br>• ឈ្វេងយល់ និងដឹងពីវិធីចៀសវាងពីការបៀតបៀនតាមប្រព័ន្ធអនឡាញ<br>Understand cyber-bullying and how to avoid it | • ចេះការពារឧបករណ៍ឌីជីថល មាតិកាឌីជីថល និងសកម្មភាពលើអ៊ីនធឺណិតផ្សេងទៀត ពីការចូលប្រើដោយគ្មានការអនុញ្ញាត ការចែករំលែកមាតិកាដោយអចេតនា និងការឃ្លាំមើលទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិកខុសច្បាប់<br>Protect devices, digital content, and other online activities against unauthorized access, accidental sharing of content, and illegal electronic surveillance.<br>• ចេះគ្រប់គ្រងលើការគិត អារម្មណ៍ និងឥរិយាបថរបស់ខ្លួន មុនពេលចែករំលែកព័ត៌មានផ្ទាល់ខ្លួនលើថ្នាលឌីជីថលណាមួយ<br>Practice self-regulation before sharing any personal information with any digital platform |

### ៧). ការដោះស្រាយបញ្ហា

**ការដោះស្រាយបញ្ហា** គឺជាសមត្ថភាពក្នុងការកំណត់ វិភាគ និងដោះស្រាយបញ្ហាប្រឈមប្រកបដោយប្រសិទ្ធភាព និងភាពច្នៃប្រឌិត។ សមត្ថភាពនេះ គូសបញ្ជាក់ពីសារៈសំខាន់នៃការយល់ដឹងអំពីហានិភ័យលើប្រព័ន្ធអនឡាញ ការចូលរួមពីទស្សនៈផ្សេងៗគ្នា ការប្រើប្រាស់បច្ចេកវិទ្យាជាយុទ្ធសាស្ត្រ និងការប្រើប្រាស់ជំនាញឌីជីថលដើម្បីបង្កើតបរិស្ថានឌីជីថលប្រកបដោយបរិយាបន្ននិងសមភាពសម្រាប់ទាំងអស់គ្នា។

**ក្នុងចង្កោមសមត្ថភាពការដោះស្រាយបញ្ហា មានសមត្ថភាព ដូចខាងក្រោម៖**

| កម្រិតមូលដ្ឋាន | កម្រិតមធ្យម | កម្រិតខ្ពស់ |
|---|---|---|
| • ទទួលស្គាល់ហានិភ័យដែលអាចកើតមានក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយឌីជីថល និងដឹងពីកន្លែងដែលត្រូវស្វែងរកជំនួយដើម្បីគ្រប់គ្រងហានិភ័យទាំងនេះ<br><br>Acknowledge possible risks in using digital media and know where to seek help to manage these risks.<br><br>• ចេះចូលរួមក្នុងការជជែកដេញដោលជាសាធារណៈ ទាក់ទងនឹងបញ្ហាសង្គម សេដ្ឋកិច្ច វប្បធម៌ ដែលប៉ះពាល់ដល់សហគមន៍ ជាពិសេសជនងាយរងគ្រោះ ដើម្បីជួយលើកកម្ពស់ការយល់ដឹងអំពីទស្សនៈផ្សេងៗគ្នានិងមនសិការសង្គម<br><br>Participate in public debate related to social, economic, cultural issues that affect members of the community, especially from vulnerable sectors, to help develop an understanding of alternative views and to promote social consciousness | • យល់អំពីគម្លាតសមត្ថភាពឌីជីថលរបស់បុគ្គលម្នាក់ៗ និងស្គាល់កន្លែងដែលត្រូវស្វែងរកជំនួយសម្រាប់ការកែលម្អ<br><br>Acknowledge personal digital competence gaps and know where to seek help for improvement<br><br>• ចេះផ្ទេរជំនាញឌីជីថលទៅដល់អ្នកដទៃ ជាពិសេសអ្នកដែលមានលទ្ធភាពមានកម្រិត<br><br>Transfer digital skills with other enthusiasts, especially those with limited access to resources | • ចេះប្រើប្រាស់កម្មវិធីរុករកទិន្នន័យ (data mining) ឬឧបករណ៍វិភាគទិន្នន័យផ្សេងទៀត (ឧទាហរណ៍ ការវិភាគ អាល់ហ្គោរីត) ជាធាតុចូលសម្រាប់ការសម្រេចចិត្តផ្អែកលើភស្តុតាង ដោយពិចារណាលើលទ្ធភាពក្នុងការទទួលបានឱកាសប្រកបដោយសមភាពនិងសមធម៌<br><br>Use data mining or other analytic tools (e.g., analytics, algorithms) as inputs for evidence-based decision-making, considering equal and equitable access to opportunities.<br><br>• ចេះបង្កើតកម្មវិធី/ដំណោះស្រាយឌីជីថលសម្រាប់ប្រយោជន៍សង្គម<br><br>Create apps/digital solutions for social good |

| កម្រិតមូលដ្ឋាន | កម្រិតមធ្យម | កម្រិតខ្ពស់ |
|---|---|---|
| • យល់ដឹងថាបណ្តាញផ្សព្វផ្សាយសង្គមនិង អ៊ីនធឺណិតគឺជាកន្លែងប្រើប្រាស់រួមគ្នា ដូច្នេះជម្លោះផ្សេងៗអាចកើតមាន<br><br>Recognize that social media and the Internet are shared spaces where conflicts are inevitable<br><br>• ចេះធ្វើឱ្យប្រសើរឡើងនូវអាល់ហ្គោរីតនៃបណ្តាញផ្សព្វផ្សាយសង្គមដែលជំរុញឱ្យមានការចូលរួមនិងលើកទឹកចិត្តតាមរយៈការកែសម្រួលការកំណត់គណនី ឬ បង្កើនជម្រើសខ្លឹមសារ ដែលកំណត់ដោយអាល់ហ្គោរីត<br><br>Gamify social media algorithms by adjusting account settings or expanding the content options beamed by the algorithm | | • យល់ដឹងថារាល់ការគំរាមកំហែងដល់សេរីភាពដែលមានការទទួលស្គាល់ជាសកល នឹងមានផលប៉ះពាល់រយៈពេលវែងលើសេរីភាពផ្ទាល់ខ្លួន<br><br>Develop a social consciousness that threats to universally accepted freedoms will have long-term repercussions on personal freedoms |

### ៨).ការសិក្សាពេញមួយជីវិត

**ការសិក្សាពេញមួយជីវិត** គឺជាសមត្ថភាពក្នុងការទទួលបានចំណេះដឹង ជំនាញ និងបទពិសោធន៍ជាប្រចាំពេញមួយជីវិតរបស់បុគ្គលម្នាក់ៗ តាមរយៈការបន្តការសិក្សារៀនសូត្រ ដើម្បីអភិវឌ្ឍសមត្ថភាព និងវិជ្ជាជីវៈផ្ទាល់ខ្លួន សម្របទៅនឹងការផ្លាស់ប្តូរស្ថានភាពនិងការវិវត្តរបស់បច្ចេកវិទ្យាយ៉ាងឆាប់រហ័ស។

**ក្នុងចង្កោមសមត្ថភាពការសិក្សាពេញមួយជីវិត មានសមត្ថភាព ដូចខាងក្រោម៖**

| កម្រិតមូលដ្ឋាន | កម្រិតមធ្យម | កម្រិតខ្ពស់ |
|---|---|---|
| • ចេះប្រើប្រាស់បច្ចេកវិទ្យា ឧបករណ៍ឌីជីថល ឬកម្មវិធីឌីជីថល ដែលសមស្រប ដើម្បីបង្កើនប្រសិទ្ធភាពការងារ<br>Use appropriate digital technologies/tools and applications to improve work efficiency<br>• ចេះចុះឈ្មោះចូលរៀនវគ្គសិក្សានានាតាមប្រព័ន្ធអនឡាញដោយឥតគិតថ្លៃ<br>Complete free online courses<br>• ចេះគ្រប់គ្រងនិងការពារទិន្នន័យដែលជាកម្មសិទ្ធិរបស់អង្គភាព (ឧទាហរណ៍ រដ្ឋាភិបាល សាជីវកម្មឯកជន)<br>Manage and protect data owned by the organization (e.g., government, private corporations, etc.) | • ចេះរៀបចំកន្លែងធ្វើការងារនិងប្រើប្រាស់លំហឌីជីថលរួមគ្នា ដើម្បីជាចំណែកនៃបរិស្ថានការងារគ្មានព្រំដែន និងមានភាពរួចរាល់សម្រាប់ ឌីជីថលូបនីយកម្ម<br>Manage the physical workspace and shared digital spaces as part of digital-ready and borderless workplaces<br>• ចេះការពារព័ត៌មានជាប់កម្មសិទ្ធិរបស់អង្គភាព ដើម្បីលើកកម្ពស់ទំនាក់ទំនងប្រកបដោយផលិតភាពជាមួយអង្គភាព<br>Protect the proprietary information of the organization to promote a productive relationship with the organization<br>• ចេះចូលរួមនិងជួយរៀបចំកម្មវិធីប្រឹក្សាយោបល់តាមប្រព័ន្ធអនឡាញ<br>Participate in/design online mentoring programs | • ចេះប្រើប្រាស់កម្មវិធីរុករកទិន្នន័យ (data mining) ដើម្បីទាញយកប្រយោជន៍ពីទិន្នន័យធំ<br>Use data mining to make sense of Big Data<br>• ចេះពីរបៀបរកប្រាក់កម្រៃពីមាតិកាដែលខ្លួនបង្កើតតាមរយៈថ្នាលឌីជីថល<br>Monetize own content using available digital platforms |

| កម្រិតមូលដ្ឋាន | កម្រិតមធ្យម | កម្រិតខ្ពស់ |
| --- | --- | --- |
| • ចេះប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយឌីជីថលសម្រាប់ការធ្វើទីផ្សារ<br>Use digital media for social marketing | • ចេះគ្រប់គ្រងតុល្យភាពរវាងការងារនិងជីវិតរស់នៅតាមប្រព័ន្ធអនឡាញ និងក្រៅប្រព័ន្ធអនឡាញ<br>Manage online-offline work-life balance<br>• ចេះធ្វើប្រតិបត្តិការដែលមិនប្រើក្រដាសពោលគឺតាមប្រព័ន្ធឌីជីថលឱ្យបានច្រើន ដើម្បីលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព និងការថែរក្សាបរិស្ថាន<br>Practice paperless or more digital transactions to promote efficiency, transparency, and environmental conservation<br>• អភិវឌ្ឍជំនាញក្នុងការអធិប្បាយសាច់រឿងឱ្យមានប្រសិទ្ធភាព ដើម្បីធ្វើបទបង្ហាញ និងយុទ្ធនាការឌីជីថល<br>Develop skills in effective storytelling for presentations and digital campaigns | |

# ៤. ការប្រើប្រាស់ក្របខណ្ឌសមត្ថភាព អ.ឌ.ប.ព.

ក្របខណ្ឌសមត្ថភាពនេះបង្ហាញនូវទិដ្ឋភាពរួមនៃសំណុំសមត្ថភាព **អ.ឌ.ប.ព.** នៅកម្ពុជា តាមរយៈការសិក្សាអង្កេតអំពីតម្រូវការជាក់ស្តែងនៅក្នុងសង្គម ដើម្បីឆ្លើយតបទៅនឹងការវិវត្តយ៉ាងលឿន និងបញ្ហានានាដែលកើតមានឡើង។ ក្របខណ្ឌនេះអាចត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការរៀបចំវគ្គបណ្តុះបណ្តាលនានាទាំងក្នុងប្រព័ន្ធអប់រំផ្លូវការ ការបណ្តុះបណ្តាលមន្ត្រីរាជការ និងការបណ្តុះបណ្តាលតាមផ្នែកនិងតាមវិស័យ និងប្រើប្រាស់ជាឧបករណ៍មានប្រយោជន៍ផ្សេងៗទៀតជាច្រើនដូចខាងក្រោម៖

## ៤.១. ការបញ្ចូល អ.ឌ.ប.ព. នៅក្នុងការអប់រំនៅតាមគ្រឹះស្ថានសាធារណៈ និងឯកជន

ក្របខណ្ឌសមត្ថភាព **អ.ឌ.ប.ព.** អាចប្រើប្រាស់សម្រាប់ការពិនិត្យឡើងវិញនិងការអភិវឌ្ឍកម្មវិធីអប់រំ (ទាំងផ្លូវការនិងក្រៅផ្លូវការ) និងជាមូលដ្ឋានគ្រឹះក្នុងការរៀបចំមុខវិជ្ជាឌីជីថល សម្រាប់សិស្សានុសិស្សនិងនិស្សិតនៅគ្រប់កម្រិតសិក្សា។ ក្របខណ្ឌនេះ ក៏អាចត្រូវបានប្រើប្រាស់សម្រាប់ការកសាងសមត្ថភាពគ្រូបង្រៀន មន្ត្រីរាជការ និងប្រជាពលរដ្ឋ តាមរយៈមជ្ឈមណ្ឌលបណ្តុះបណ្តាលនានារបស់រាជរដ្ឋាភិបាល សាលាភូមិន្ទរដ្ឋបាល វិទ្យាស្ថានអភិបាលកិច្ចឌីជីថលនៃបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា បណ្ឌិត្យសភានគរបាលកម្ពុជា ការបណ្តុះបណ្តាលនានាដែលធ្វើឡើងដោយសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងក្រុមហ៊ុនឯកជននានាដែលមានតម្រូវការចាំបាច់ក្នុងការបណ្តុះបណ្តាលនិងលើកកម្ពស់កម្រិតសមត្ថភាព **អ.ឌ.ប.ព.** របស់ក្រុមគោលដៅ ឬ បុគ្គលិករបស់ខ្លួន។

ក្របខណ្ឌសមត្ថភាព **អ.ឌ.ប.ព.** អាចត្រូវបានប្រើប្រាស់ដើម្បីជំរុញការចូលរួមរបស់សហគមន៍ ដោយផ្តល់នូវភាសាសាមញ្ញនិងបង្ហាញនូវសមត្ថភាពចាំបាច់នានាសម្រាប់បុគ្គលនិងស្ថាប័ន ក្នុងការចូលរួមការពិភាក្សាលើសកម្មភាពដែលទាក់ទងនឹង **អ.ឌ.ប.ព.**។ សកម្មភាពនេះអាចជួយកសាងស្មារតីសហគមន៍គោលបំណងរួមគ្នាជុំវិញ **អ.ឌ.ប.ព.** និងលើកទឹកចិត្តបុគ្គលម្នាក់ៗឱ្យចូលរួមយ៉ាងសកម្មក្នុងការលើកកម្ពស់ និងជំរុញ **អ.ឌ.ប.ព.** នៅក្នុងសហគមន៍មូលដ្ឋាន។

## ៤.២. ការវាយតម្លៃកម្មវិធី ឬ កម្មវិធីសិក្សាដែលមានស្រាប់ពាក់ព័ន្ធនឹង អ.ឌ. និងអ.ប.ព.

ក្របខណ្ឌសមត្ថភាព **អ.ឌ.ប.ព.** គឺជាឧបករណ៍រួមមួយ ដែលអាចប្រើប្រាស់សម្រាប់វាយតម្លៃនិងពិនិត្យឡើងវិញនូវគំនិតផ្តួចផ្តើមនានា និងកម្មវិធីអភិវឌ្ឍសមត្ថភាពឌីជីថលមានស្រាប់នាពេលបច្ចុប្បន្ន ឬ វាយតម្លៃជំនាញឌីជីថលកំពុងត្រូវបានអនុវត្តនៅទូទាំងក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ដើម្បីចាប់យកកាលានុវត្តភាពឧត្តមានុវត្តន៍ កំណត់ចំណុចត្រូវកែលម្អ និងពង្រីកវិសាលភាពនៃកម្មវិធីដែលមានស្រាប់។

នៅក្នុងរូបភាពទូលំទូលាយជាងនេះ ក្របខណ្ឌសមត្ថភាពអាចត្រូវប្រើប្រាស់ជាមូលដ្ឋានសម្រាប់បង្កើតឧបករណ៍វាយតម្លៃ ដើម្បីវាស់វែង ឬ ត្រួតពិនិត្យសមត្ថភាព **អ.ឌ.ប.ព.** របស់ប្រជាពលរដ្ឋ អ្នកអប់រំ មន្ត្រីរាជការ ឬ ក្រុមគោលដៅដទៃទៀត។ ការវាយតម្លៃសមត្ថភាព **អ.ឌ.ប.ព.** នៃក្រុមគោលដៅណាមួយ នឹងបម្រើដល់ការបង្កើតគំរូស្តង់ដា ដើម្បីវាស់វែងវឌ្ឍនភាពនៃកម្មវិធីលើកកម្ពស់សមត្ថភាព **អ.ឌ.ប.ព.** ក្នុងរយៈពេលជាក់លាក់ណាមួយ ឬដើម្បីវាស់វែងប្រសិទ្ធភាពនៃកម្មវិធីបណ្តុះបណ្តាល **អ.ឌ.ប.ព.** ជាក់លាក់ ឬ **អ.ឌ.ប.ព.** ដែលទាក់ទងនឹងកិច្ចអន្តរាគមន៍ ឬ គំនិតផ្តួចផ្តើមនានា។

## ៤.៣. ការអភិវឌ្ឍគោលនយោបាយ ឬ យុទ្ធសាស្ត្រ

ក្របខណ្ឌសមត្ថភាព **អ.ឌ.ប.ព.** អាចត្រូវបានប្រើប្រាស់ជាមូលដ្ឋានមួយសម្រាប់ការអភិវឌ្ឍគោលនយោបាយ យុទ្ធសាស្ត្រ ឬ ផែនការសកម្មភាពផ្អែកលើព័ត៌មានគ្រប់ជ្រុងជ្រោយនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយផ្តល់នូវការយល់ដឹងច្បាស់លាស់អំពីសមត្ថភាពនានាដែលបុគ្គលម្នាក់ៗនិងស្ថាប័ននីមួយៗត្រូវមាននៅក្នុងយុគសម័យឌីជីថល។ តាមរយៈសំណុំសមត្ថភាព ឬ លទ្ធផលនៃការវាយតម្លៃកម្រិតសមត្ថភាពនៃក្របខណ្ឌរួមមួយ សុទ្ធតែមានគុណតម្លៃបម្រើដល់ការដាក់ចេញនូវគោលនយោបាយ និងសកម្មភាពប្រកបដោយប្រសិទ្ធភាព ដូចជា៖

- ផលិតឯកសារលើកកម្ពស់ការយល់ដឹង ឬ ព័ត៌មាន-ការអប់រំ-ទំនាក់ទំនង (IEC) ទៅតាមប្រភេទសមត្ថភាពនៃ **អ.ឌ.ប.ព.**
- បង្កើតសូចនាករសមិទ្ធកម្មដែលអាចវាស់វែងបាន ដោយផ្អែកលើចង្កោមសមត្ថភាពនៃ **អ.ឌ.ប.ព.** ដែលត្រូវការ
- ធ្វើបច្ចុប្បន្នភាពនិងពង្រឹងការរៀបចំផែនទីអក្ខរកម្មមូលដ្ឋាន និងមុខងារជាប្រចាំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (ដោយបញ្ចូលសូចនាករដែលទាក់ទងនឹង **អ.ឌ.ប.ព.**)
- រៀបចំផែនការស្រាវជ្រាវ **អ.ឌ.ប.ព.** និងកំណត់បញ្ហាដែលត្រូវដោះស្រាយ។

# ៥. សេចក្តីសន្និដ្ឋាន

អក្ខរកម្មឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន (**អ.ឌ.ប.ព.**) ដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថលប្រកបដោយបរិយាបន្ន។ ប្រជាពលរដ្ឋដែលមានសមត្ថភាព **អ.ឌ.ប.ព.** នឹងក្លាយជាអ្នកចូលរួមយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាល វិស័យឯកជន និងស្ថាប័នសម្របសម្រួលផ្សេងទៀត តាមរយៈសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាឌីជីថលប្រកបដោយការទទួលខុសត្រូវ សុវត្ថិភាព និងប្រសិទ្ធភាព ដែលទាំងអស់នេះជាមូលដ្ឋាននិងជាកត្តាជំរុញបន្ថែមនូវគោលការណ៍នីតិរដ្ឋ បរិយាបន្ន រដ្ឋាភិបាលឌីជីថល កិច្ចសហប្រតិបត្តិការឌីជីថល ការសិក្សាពេញមួយជីវិត កម្មសិទ្ធិបញ្ញា និងសេរីភាពនៃការបញ្ចេញមតិ និងការទទួលបានព័ត៌មាន។ លើសពីនេះទៀត **អ.ឌ.ប.ព.** រក្សានូវស្នាដៃនិងគុណតម្លៃនៃសន្តិភាពនិងស្ថិរភាព សមភាពយេនឌ័រ សេរីភាពបញ្ចេញមតិនិងការទទួលខុសត្រូវ ពហុនិយមនិងភាពចម្រុះ ការគោរពនិងយោគយល់គ្នា ការយល់អារម្មណ៍ សុចរិតភាព និងសុភវិនិច្ឆ័យ។ គោលការណ៍និងគុណតម្លៃទាំងនេះគឺជាអ្វីដែលពលរដ្ឋកម្ពុជាត្រូវប្រកាន់ខ្ជាប់ ក្នុងដំណើរប្រែក្លាយខ្លួនជា “ពលរដ្ឋឌីជីថល”។ ក្របខណ្ឌសមត្ថភាព **អ.ឌ.ប.ព.** គឺជាឧបករណ៍ចាំបាច់ក្នុងដំណើរអភិវឌ្ឍពលរដ្ឋឌីជីថល ប្រកបដោយសង្គតិភាព ប្រសិទ្ធភាព និងបរិយាបន្ន ស្របតាមទិសដៅរបស់រាជរដ្ឋាភិបាលកម្ពុជានិងស្តង់ដាអន្តរជាតិ។

## ឧបសម្ព័ន្ធ សទ្ទានុក្រម

| ល.រ | ភាសាអង់គ្លេស | ភាសាខ្មែរ | និយមន័យ |
| --- | --- | --- | --- |
| ១ | 5G | បច្ចេកវិទ្យាទូរសព្ទចល័តជំនាន់ទី៥ | បច្ចេកវិទ្យាទូរសព្ទចល័តជំនាន់ថ្មី ដោយរួមបញ្ចូលទាំងស្តង់ដា វិធីសាស្ត្រ នីតិវិធី និយ័តកម្ម សុសវែរ សម្ភារៈបរិក្ខារ និងបណ្តាញ ទូរសព្ទចល័ត ដែលតភ្ជាប់ទៅនឹងប្រព័ន្ធអ៊ីនធឺណិត ហើយអាចផ្តល់ល្បឿនក្នុងការបញ្ជូនទិន្នន័យរហូតដល់ ១០ ជីហ្គាបិត ក្នុង ១ វិនាទី (Gb/s)។ |
| ២ | Algorithm | អាល់ហ្គោរីត | ក្បួនដោះស្រាយបញ្ហាដោយប្រើប្រាស់បណ្តា កម្មវិធីនិង/ឬ គោលការណ៍នានា។ |
| ៣ | Alternative Media | ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ | ប្រព័ន្ធផ្សព្វផ្សាយដែលមានប្រភពព័ត៌មាន ឯករាជ្យ ដោយមិនទទួលឥទ្ធិពលពីរដ្ឋាភិបាល ស្ថាប័ន ឬ សហគ្រាសណាមួយ និងជាប្រព័ន្ធផ្សព្វផ្សាយផ្សេងពីប្រព័ន្ធផ្សព្វផ្សាយធំៗ។ |
| ៤ | Artificial Intelligence (AI) | បញ្ញាសិប្បនិម្មិត | វិធីសាស្ត្រ កម្មវិធី ឬ ផលិតផលជាម៉ាស៊ីននិងសុសវែរ ដែលមានលក្ខណៈឆ្លាតវៃដូចមនុស្ស ដូចជាសមត្ថភាពក្នុងការប្រើប្រាស់ភាសាធម្មជាតិ ការសិក្សា ការវិភាគ ការសម្រេចចិត្ត និងការដោះស្រាយបញ្ហានានា។ |
| ៥ | Augmented Reality (AR) | បច្ចេកវិទ្យាតថភាពបន្ថែម ឬ អេអ | ការរួមបញ្ចូលព័ត៌មានឌីជីថលបន្ថែម តាមរយៈការប្រើប្រាស់ឧបករណ៍និងកម្មវិធីឌីជីថល ដើម្បីជាជំនួយឱ្យអ្នកប្រើប្រាស់ទទួលបានអារម្មណ៍ពីតថភាពមួយ (ការរៀបចំ) ដូចនៅក្នុងបរិស្ថានពិតជាក់ស្តែង។ |
| ៦ | Big Data | ទិន្នន័យធំ | សំណុំទិន្នន័យដែលមានបរិមាណច្រើនសន្ធឹកសន្ធាប់ ច្រើនសណ្ឋាន ច្រើនប្រភព ច្រើនប្រភេទ តែជាទូទៅគ្មានរចនាសម្ព័ន្ធច្បាស់លាស់ ដែលតម្រូវឱ្យមានវិធីសាស្ត្រនិងបច្ចេកវិទ្យាពិសេសសម្រាប់គ្រប់គ្រងនិងវិភាគលើទិន្នន័យទាំងនោះ សម្រាប់ជាជំនួយដល់ការសម្រេចចិត្ត និងបម្រើផលប្រយោជន៍ផ្សេងៗទៀត។ |
| ៧ | Blockchain Technology | បច្ចេកវិទ្យាប្លុកឆេន | បច្ចេកវិទ្យានៃហេដ្ឋារចនាសម្ព័ន្ធផ្ទុកទិន្នន័យជាខ្សែច្រវាក់តភ្ជាប់គ្នាពីមួយទៅមួយដោយសុវត្ថិភាព ដែលមិនត្រូវការកែប្រែ ហើយទិន្នន័យទាំងនោះនឹងត្រូវចម្លងដើម្បីផ្ទុកនៅតាមបណ្តាម៉ាស៊ីនមេដែលចូលរួមក្នុងហេដ្ឋារចនាសម្ព័ន្ធផ្ទុកទិន្នន័យនេះក្នុងទម្រង់បែបវិមជ្ឈការ។ |
| ៨ | Cloud Technology | បច្ចេកវិទ្យាក្លោដ ឬ ពពក | បច្ចេកវិទ្យាដែលផ្តល់លទ្ធភាពដល់ការប្រើប្រាស់និងចែករំលែកធនធានគណនា ធនធានបណ្តាញ ធនធានផ្ទុកទិន្នន័យ ធនធានសុសវែរ និងថ្នាលអភិវឌ្ឍន៍សុសវែរ តាមប្រព័ន្ធអ៊ីនធឺណិតប្រកបដោយប្រសិទ្ធភាពស្របទៅតាមតម្រូវការ ដោយអ្នកប្រើប្រាស់មិនចាំបាច់គ្រប់គ្រងធនធានទាំងនោះដោយផ្ទាល់។ |

| | | | |
|---|---|---|---|
| ៩ | Community Standards | ស្តង់ដាសហគមន៍ | ស្តង់ដា ឬ គោលការណ៍ណែនាំដែលគូសបញ្ជាក់អំពីប្រភេទខ្លឹមសារអន្តរកម្ម និងអាកប្បកិរិយាដែលអាចទទួលយកបាននិងមិនអាចទទួលយកបាននៅក្នុងសហគមន៍អនឡាញ ជាពិសេសនៅលើបណ្ដាញផ្សព្វផ្សាយសង្គម ដើម្បីធានាបាននូវសុវត្ថិភាព ការគោរព និងការរួមបញ្ចូលមតិយោបល់របស់អ្នកដទៃ។ |
| ១០ | Competency | សមត្ថភាព | សមត្ថភាពរបស់បុគ្គលក្នុងការប្រមូលផ្ដុំ និងប្រើប្រាស់ធនធានខាងក្នុងខ្លួនដូចជា ចំណេះដឹង ជំនាញ និងអាកប្បកិរិយា ព្រមទាំង ធនធានខាងក្រៅដូចជាមិត្តភក្តិ បណ្ណាល័យ ឧបករណ៍ និងស្ថាប័នផ្សេងៗ ដើម្បីដោះស្រាយបញ្ហាជាក់លាក់មួយប្រកបដោយប្រសិទ្ធភាពក្នុងស្ថានភាពជីវិតជាក់ស្តែង។ |
| ១១ | Cybersecurity | សន្តិសុខសាយប័រ | ការអនុវត្តនៃការទប់ស្កាត់ ការឆ្លើយតប និងការការពារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន រួមទាំង ហេដ្ឋារចនាសម្ព័ន្ធ បណ្ដាញ ប្រព័ន្ធប្រតិបត្តិការ និងកម្មវិធី ពីការជ្រៀតចូលនិងការវាយប្រហារគ្រប់រូបភាព ជាពិសេសតាមប្រព័ន្ធអ៊ីនធឺណិត។ |
| ១២ | Data | ទិន្នន័យ | សញ្ញាណ ឬ សារ ក្នុងទម្រង់ជាអត្ថបទ រូបភាព សំឡេង ឬវីដេអូ ដែលត្រូវបានរៀបចំក្នុងទម្រង់សមស្របសម្រាប់ប្រើប្រាស់ក្នុងមូលទិន្នន័យ ឬ ប្រព័ន្ធអេឡិចត្រូនិក។ |
| ១៣ | Data Mining | ការរុករកទិន្នន័យ | ដំណើរការនៃវិភាគទិន្នន័យដែលមានទំហំធំនិងព្យាករណ៍ព័ត៌មានដោយប្រើវិធីសាស្ត្រនិងឧបករណ៍ឌីជីថលទំនើប។ |
| ១៤ | Database | មូលដ្ឋានទិន្នន័យ | បណ្ដុំទិន្នន័យដែលមានទំនាក់ទំនងគ្នាបង្កើតឡើងក្នុងគោលបំណងងាយស្រួលគ្រប់គ្រង និងស្វែងរក។ |
| ១៥ | Digital Citizen | ពលរដ្ឋឌីជីថល | ប្រជាពលរដ្ឋដែលចេះប្រើប្រាស់បច្ចេកវិទ្យា ឌីជីថលក្នុងកិច្ចការ និងការរស់នៅប្រចាំថ្ងៃ ប្រកបដោយសុវត្ថិភាពនិងការទទួលខុសត្រូវ។ |
| ១៦ | Digital Content | មាតិកាឌីជីថល | មាតិកានៃព័ត៌មានក្នុងទម្រង់ឌីជីថល ដែលអាចមើល អាន ស្ដាប់ ឬ ទាញយកបានក្នុងទម្រង់ជាអត្ថបទ រូបភាព សំឡេង ឬវីដេអូ ។ល។ |
| ១៧ | Digital Cooperation | កិច្ចសហប្រតិបត្តិការឌីជីថល | សំដៅលើកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងចំណោមភាគីពាក់ព័ន្ធដូចជារដ្ឋាភិបាល វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍បច្ចេកទេស ដើម្បីបង្កើនប្រសិទ្ធភាព ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល រួមមាន៖ ការសម្រេចបាននូវការតភ្ជាប់ជាសកល ការលើកកម្ពស់ទំនិញសាធារណៈឌីជីថល បរិយាបន្នឌីជីថល និងការការពារសិទ្ធិមនុស្សក្នុងយុគសម័យឌីជីថល។ |
| ១៨ | Digital Footprint | ដានជើងឌីជីថល | ស្លាកស្នាមទិន្នន័យដែលកើតចេញពីការប្រើប្រាស់អ៊ីនធឺណិតរបស់រូបវន្តបុគ្គលណាមួយ ដូចជា ការប្រើប្រាស់វិបសាយ អ៊ីម៉ែល ឬ ព័ត៌មានផ្សេងៗតាមអនឡាញ ។ |

| | | | |
|---|---|---|---|
| ១៩ | Digital Government | រដ្ឋាភិបាល ឌីជីថល | ដំណើរការនៃការធ្វើទំនើបកម្មលើប្រព័ន្ធគ្រប់គ្រងរដ្ឋាភិបាលនិងសេវាសាធារណៈ តាមរយៈការប្រើប្រាស់នូវបច្ចេកវិទ្យាឌីជីថល ដូចជា កុំព្យូទ័រ ឧបករណ៍ឆ្លាត និងប្រព័ន្ធអ៊ីនធឺណិត សំដៅជួយសម្រួលដល់ការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់រដ្ឋ ការសម្រេចចិត្ត និងការផ្តល់សេវាជូន ប្រជាពលរដ្ឋ វិស័យឯកជន និងស្ថាប័ន ពាក់ព័ន្ធនានាប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងបរិយាបន្នកម្ម។ |
| ២០ | Digital Identity | អត្តសញ្ញាណ ឌីជីថល | ព័ត៌មានក្នុងទម្រង់ឌីជីថលសម្រាប់កំណត់ អត្តសញ្ញាណបុគ្គល ឬ វត្ថុ តាមរយៈការធ្វើស្វ័យប្រវត្តិកម្មការងារ (ការវាយតម្លៃ និងការផ្ទៀងផ្ទាត់) ដោយប្រព័ន្ធកុំព្យូទ័រ។ |
| ២១ | Digital Literacy | អក្ខរកម្ម ឌីជីថល | ជាការចេះប្រើប្រាស់ឧបករណ៍ឌីជីថលប្រកបដោយភាពវិជ្ជមាន, ការទទួលខុសត្រូវ, ប្រសិទ្ធភាព, និងសុវត្ថិភាព ដើម្បីកំណត់, ឈ្វេងយល់, វាយតម្លៃ, បង្កើត, និងចែករំលែកមាតិកាឌីជីថល ព្រមទាំងការសិក្សាឈ្វេងយល់ពីរបៀបដែលប្រព័ន្ធឌីជីថល ដំណើរការក្នុងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ប្រកបដោយបរិយាបន្ន។ |
| ២២ | Digital Space | លំហឌីជីថល | គថភាពអនឡាញ ឬ បរិស្ថាននិម្មិត ដែលត្រូវបានបង្កើតចេញពីបច្ចេកវិទ្យាឌីជីថល។ |
| ២៣ | Digital Transformation | បរិវត្តកម្ម ឌីជីថល | ដំណើរការនៃការផ្លាស់ប្តូរអភិបាលកិច្ច ធុរកិច្ច និងដំណើរការការងារ តាមរយៈឌីជីថលនីយកម្មដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងប្រសិទ្ធផលក្នុងស្ថាប័ន សេដ្ឋកិច្ច និងសង្គម។ |
| ២៤ | Digitalization | ឌីជីថលនីយកម្ម ឬ ឌីជីថលរូបនីយកម្ម | ដំណើរការនៃការកែសម្រួលអភិបាលកិច្ច ធុរកិច្ច ឬដំណើរការការងារឱ្យមានប្រសិទ្ធភាពនិងប្រសិទ្ធផល តាមរយៈការប្រើប្រាស់បច្ចេកវិទ្យា ឌីជីថលនិងទិន្នន័យក្នុងទម្រង់ឌីជីថល។ |
| ២៥ | Discernment | សុភវិនិច្ឆ័យ | ជាការប្រើប្រាស់បញ្ញាញាណ បទពិសោធន៍ និងពុទ្ធិផ្ទាល់ខ្លួន ដើម្បីធ្វើការសម្រេចចិត្តនិងការវិនិច្ឆ័យឱ្យបានត្រឹមត្រូវ។ |
| ២៦ | Disinformation | ព័ត៌មាន មិនពិត | ព័ត៌មានមិនពិត ឬ មិនស្មោះត្រង់ដែលកើតចេញពីការប៉ុនប៉ងដោយចេតនា (មានការរៀបចំទុក) ដើម្បីបំភាន់ ឬ បោកប្រាស់មនុស្ស។ ព័ត៌មានមិនពិតជាញឹកញាប់មានការរៀបចំ មានធនធានគ្រប់គ្រាន់ មានបច្ចេកវិទ្យាស្វ័យប្រវត្តិ ដើម្បីជួយពង្រីង។ |

| | | | |
|---|---|---|---|
| ២៧ | DMIL Ecosystem | ប្រព័ន្ធអេកូឡូស៊ីនៃអក្ខរកម្មឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន | ប្រព័ន្ធរួមមួយ ដែលមានសមាសភាពដូចជា អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ អក្ខរកម្មព័ត៌មាន អក្ខរកម្មសារព័ត៌មាន អក្ខរកម្មបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ អក្ខរកម្មឌីជីថល អក្ខរកម្មភាពយន្ត/រោងកុន អក្ខរកម្មផ្នែកផ្សាយពាណិជ្ជកម្ម និងអក្ខរកម្មបណ្ណាល័យក្នុងចំណោមអក្ខរកម្មដទៃទៀត ដោយការរួមបញ្ចូលគ្នានៃធាតុទាំងនេះបានបង្ហាញពីសំណុំសមត្ថភាពដែលចាំបាច់សម្រាប់ជីវិត និងការងារនាពេលបច្ចុប្បន្ន។ |
| ២៨ | DMIL Service Providers | អ្នកផ្តល់សេវាលើកកម្ពស់អក្ខរកម្មឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន | ទីភ្នាក់ងារ ឬ អង្គការដែលចូលរួមក្នុងការងារ អ.ឌ.ប.ព. រួមមានការកសាងសមត្ថភាព (ការអប់រំនិងការបណ្តុះបណ្តាល) ការអភិវឌ្ឍសម្ភារៈបង្រៀន ការស្រាវជ្រាវ និងការតស៊ូមតិ។ ទីភ្នាក់ងារ ឬ អង្គការទាំងនេះអាចជារដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នសិក្សា ឬ ទីភ្នាក់ងារសារព័ត៌មាន។ |
| ២៩ | DMIL Stakeholders | ភាគីពាក់ព័ន្ធនៃអក្ខរកម្មឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន | បុគ្គល ក្រុម ឬ វិស័យផ្សេងៗដែលពាក់ព័ន្ធនឹងការកសាងសមត្ថភាពផ្នែក អ.ឌ.ប.ព. ដើម្បីឱ្យពួកគេអាចអនុវត្តសមត្ថភាព អ.ឌ.ប.ព. ដែលត្រូវការក្នុងការបំពេញកាតព្វកិច្ចជាបុគ្គល គ្រួសារ សហគមន៍ និងសង្គម។ |
| ៣០ | Empathy | ការយល់អារម្មណ៍ | ជាសមត្ថភាពមួយដែលអាចឱ្យយើងយល់ពីអារម្មណ៍អ្នកដទៃចេះយល់ចិត្ត និងសម្របខ្លួនបានល្អ។ |
| ៣១ | Freedom and Responsibility | សេរីភាព និងការទទួលខុសត្រូវ | សំដៅលើសេរីភាពក្នុងការជ្រើសរើសការអនុវត្តសកម្មភាពណាមួយ រួមទាំងសិទ្ធិក្នុងការទទួលព័ត៌មាននិងការបញ្ចេញមតិដោយមានការទទួលខុសត្រូវទាំងផ្នែក សីលធម៌និងផ្នែកគតិយុត្ត។ |
| ៣២ | Freedom of Expression and Freedom of Information | សេរីភាពនៃការបញ្ចេញមតិនិងការទទួលបានព័ត៌មាន | ជាសិទ្ធិក្នុងការស្វែងរក ទទួល និងចែកចាយព័ត៌មាន ឬ គំនិតគ្រប់បែបយ៉ាង តាមមធ្យោបាយផ្សេងៗ តាមរយៈផ្ទាល់មាត់ក្តី ការសរសេរ ឬ បោះពុម្ពក្តី ក្នុងទម្រង់សិល្បៈ ឬ តាមរយៈប្រព័ន្ធផ្សព្វផ្សាយណាមួយ។ |
| ៣៣ | Gender Equality | សមភាពយេនឌ័រ | សំដៅទៅលើភាពគ្មានការរើសអើង ដែលប្រកាន់លើភេទណាមួយនៅក្នុងការបែងចែកធនធានផលប្រយោជន៍ ឬ នៅក្នុងការទទួលបានសេវានានា។ សមភាពយេនឌ័រអាចវាស់វែងបានដោយការពិនិត្យមើលអំពីការមានកាលានុវត្តភាពស្មើគ្នា ឬ ការទទួលបាននូវលទ្ធផលដូចគ្នារបស់ស្ត្រីនិងបុរស។ ក្នុងនោះសំដៅលើភាពស្មើគ្នាលើ ការចូលរួម ការទទួលបានការគ្រប់គ្រង និងការធ្វើសេចក្តីសម្រេចរវាងបុរសនិងស្ត្រី ទៅលើធនធានទ្រព្យសម្បត្តិ និងសកម្មភាពផ្សេងៗក្នុងវិស័យសាធារណៈនិងឯកជន។ |

| | | | |
|---|---|---|---|
| ៣៤ | Gender Equity | សមធម៌យេនឌ័រ | ជាដំណើរការនៃការប្រព្រឹត្តដោយយុត្តិធម៌ទៅលើស្ត្រីនិងបុរស សំដៅឆ្ពោះទៅសមភាពយេនឌ័រតាមរយៈគោលនយោបាយ ច្បាប់ និងវិធានការនានា ដើម្បីកែសម្រួលនូវភាពលម្អៀងដែលមាននៅក្នុងសង្គមចំពោះស្ត្រី និងបុរស។ ក្នុងនោះ សំដៅលើវិធានការ ឬសកម្មភាពពិសេសជាក់លាក់ក្នុងការបង្កឱកាស ការលើកទឹកចិត្តការជំរុញ ដើម្បីឈានទៅរកភាពស្មើគ្នារវាងបុរសនិងស្ត្រីនៅក្នុងការងារសង្គម និងនៅក្នុងគ្រួសារ (សមភាពយេនឌ័រ)។ |
| ៣៥ | Hate Speech | សំដីស្អប់ខ្ពើម | ប្រភេទនៃទំនាក់ទំនងណាមួយនៅក្នុងការនិយាយ ការសរសេរ ឬអាកប្បកិរិយា ដែលវាយប្រហារ ឬ ប្រើភាសាប្រមាថ ឬ រើសអើងទៅលើបុគ្គល ឬ ក្រុមណាមួយដោយផ្អែកលើសាសនា ជាតិសាសន៍ សញ្ជាតិ ពណ៌សម្បុរ ពូជសាសន៍ យេនឌ័រ ឬ កត្តាអត្តសញ្ញាណផ្សេងទៀត។ |
| ៣៦ | Inclusion | បរិយាបន្ន | ជាការរួមបញ្ចូលគ្រប់ក្រុមមនុស្ស ដោយមិនប្រកាន់ពីភេទ អាយុ ពណ៌សម្បុរ កម្រិតសិក្សា មុខរបរ សាសនា កាយសម្បទា និងសញ្ជាតិ ទៅក្នុងគ្រប់សកម្មភាពសេដ្ឋកិច្ច សង្គម ហើយពួកគេមានឱកាសនិងសិទ្ធិស្មើៗគ្នា។ |
| ៣៧ | Information | ព័ត៌មាន | សញ្ញាណ ឬ សារ ក្នុងទម្រង់ជាអត្ថបទ រូបភាព សំឡេង ឬវីដេអូ ដែលអ្នកប្រើប្រាស់អាចទទួលដឹងនិងអាចប្រើប្រាស់សម្រាប់ជាជំនួយដល់ការសម្រេចចិត្ត ការសិក្សាស្រាវជ្រាវ ឬការកំសាន្ត។ |
| ៣៨ | Information Disorder | ព័ត៌មានច្របូកច្របល់ | ព័ត៌មានមិនពិត(Disinformation) ដោយការបញ្ឆោត (Mal-information) ឬ ព័ត៌មានខុស (Misinformation) ដែលអាចបង្កព្យសនកម្ម ឬ គ្រោះថ្នាក់ដល់បុគ្គលណាម្នាក់ ស្ថាប័នណាមួយ ឬ ប្រទេសជាតិទាំងមូល។ |
| ៣៩ | Information Literacy | អក្ខរកម្មព័ត៌មាន | សមត្ថភាពក្នុងការកំណត់និយមន័យ និងបញ្ជាក់តម្រូវការព័ត៌មាន ស្វែងរកនិងចូលប្រើព័ត៌មាន ចូលប្រើប្រាស់ វាយតម្លៃ និងរៀបចំព័ត៌មាន ប្រើប្រាស់ព័ត៌មានប្រកបដោយប្រសិទ្ធភាព និងប្រើប្រាស់ព័ត៌មានដើម្បីទំនាក់ទំនង ក្នុងទម្រង់ផ្សេងៗ។ |
| ៤០ | Integrity | សុចរិតភាព | ជាការប្រព្រឹត្តល្អទាំង ៣ យ៉ាងគឺ ការប្រព្រឹត្តល្អដោយកាយ ហៅកាយសុចរិត ដោយវាចា ហៅវចីសុចរិត ដោយចិត្តសុទ្ធ ហៅមនោសុចរិត។ |

| | | | |
|---|---|---|---|
| ៤១ | Intellectual Property | កម្មសិទ្ធិបញ្ញា | សំដៅទៅលើការបង្កើតគំនិតដូចជា ការបង្កើតការងារផ្នែកអក្សរសាស្ត្រនិងសិល្បៈ និងនិមិត្តសញ្ញាឈ្មោះរូបភាពនិងម៉ូដបានប្រើនៅក្នុងពាណិជ្ជកម្ម។ |
| ៤២ | Internet | អ៊ីនធឺណិត | បណ្តាញនិងអន្តរបណ្តាញបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានដែលបានតភ្ជាប់គ្នា ទូទាំងពិភពលោកសម្រាប់គាំទ្រដល់ការប្រាស្រ័យទាក់ទង ការបំពេញការងារ ការធ្វើពាណិជ្ជកម្ម ការសិក្សា និងការកំសាន្ត។ |
| ៤៣ | Internet of Things | អ៊ីនធឺណិតនៃវត្ថុ | បណ្តាញនៃវត្ថុដែលត្រូវបានតភ្ជាប់ដោយអ៊ីនធឺណិត មានមុខងារចាប់សញ្ញា និង អាចធ្វើអន្តរកម្មជាមួយវត្ថុផ្សេងៗទៀត ឬ មជ្ឈដ្ឋានខាងក្រៅ ។ |
| ៤៤ | Lifelong Learning | ការសិក្សាពេញមួយជីវិត | ជាការទទួលបានចំណេះដឹង ជំនាញ និងបទពិសោធន៍ជាប្រចាំពេញមួយជីវិតរបស់បុគ្គលម្នាក់ៗ តាមរយៈការបន្តការសិក្សារៀនសូត្រ ដើម្បីអភិវឌ្ឍសមត្ថភាព និងវិជ្ជាជីវៈផ្ទាល់ខ្លួន សម្របទៅនឹងការផ្លាស់ប្តូរស្ថានភាព និងការវិវត្តរបស់បច្ចេកវិទ្យាយ៉ាងឆាប់រហ័ស។ |
| ៤៥ | Machine Learning | ម៉ាស៊ីនស្វ័យសិក្សា | បច្ចេកវិទ្យាមួយនៃបញ្ញាសិប្បនិម្មិត ដែលផ្តល់សមត្ថភាពឱ្យម៉ាស៊ីនក្នុងការសិក្សា ការទទួលស្គាល់ និងការព្យាករណ៍លទ្ធផល ឬ សមិទ្ធកម្មបានកាន់តែត្រឹមត្រូវ និងល្អប្រសើរប្រកបដោយស្វ័យភាព ដោយផ្អែកលើទិន្នន័យដែលត្រូវបានធ្វើប្រព្រឹត្តិកម្មដោយមិនចាំបាច់មានការធ្វើកម្មវិធីនីយកម្មច្បាស់លាស់ដើម្បីធ្វើដូច្នោះឡើយ ។ |
| ៤៦ | Media | ប្រព័ន្ធផ្សព្វផ្សាយ ឬ មេឌា | ឧបករណ៍ ឬ មធ្យោបាយក្នុងការផ្សព្វផ្សាយ និងចែករំលែកព័ត៌មាន ដែលមានដូចជាកាសែត ទស្សនាវដ្តី វិទ្យុ ទូរទស្សន៍ អ៊ីនធឺណិត និងបណ្តាញផ្សព្វផ្សាយសង្គមជាដើម។ |
| ៤៧ | Media and Information Literacy (MIL) | អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន | ជាសំណុំសមត្ថភាពដែលផ្តល់សិទ្ធិអំណាចដល់ពលរដ្ឋក្នុងការឈ្វេងយល់អំពីមុខងារនៃប្រព័ន្ធផ្សព្វផ្សាយ និងអាក់សេស, ប្រើប្រាស់, ជ្រើសរើស, វាយតម្លៃ, រៀបចំ, ចែករំលែក, និងបង្កើតមាតិកាលើប្រព័ន្ធផ្សព្វផ្សាយ និងពីប្រភពព័ត៌មានផ្សេងៗ ប្រកបដោយការត្រិះរិះពិចារណា ក្រមសីលធម៌ ប្រសិទ្ធភាព និងការទទួលខុសត្រូវ។ |

| | | | |
|---|---|---|---|
| ៤៨ | Media Literacy | អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ | ជាសមត្ថភាពក្នុងការយល់ដឹងនិងវិភាគ សាររបស់ប្រព័ន្ធផ្សព្វផ្សាយ។ សមត្ថភាពនេះចាំបាច់សម្រាប់ប្រជាពលរដ្ឋក្នុងការទទួលព័ត៌មាននិងការចូលរួមនៅក្នុងសង្គមប្រជាធិបតេយ្យ។ ចំណេះដឹងផ្នែកប្រព័ន្ធផ្សព្វផ្សាយរួមមានការយល់ដឹងអំពីតួនាទីនៃប្រព័ន្ធផ្សព្វផ្សាយនៅក្នុងសង្គម, ការវាយតម្លៃខ្លឹមសារប្រព័ន្ធផ្សព្វផ្សាយ, និងការផលិតនិងការចែករំលែកបទអត្ថាធិប្បាយដើម្បីឆ្លើយតបត្រឡប់វិញ។ |
| ៤៩ | Misinformation | ព័ត៌មានខុស | ព័ត៌មានបែបនាំឱ្យយល់ខុស ដែលត្រូវបានបង្កើតឡើង ឬផ្សព្វផ្សាយដោយគ្មានចេតនាបំភ្លៃ ឬ បំណងអាក្រក់។ |
| ៥០ | News | ដំណឹង | ព័ត៌មានថ្មីៗ ឬ មានសារៈសំខាន់ ដែលត្រូវបានផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ ឬ របបសារព័ត៌មាន ។ |
| ៥១ | Pluralism and Diversity | ពហុនិយមនិងភាពចម្រុះ | សំដៅលើជម្រើសនានាសម្រាប់សាធារណជនក្នុងការទទួលបានព័ត៌មាន និងចូលរួមផ្តល់ជាទស្សនៈផ្សេងៗពាក់ព័ន្ធនឹងវប្បធម៌សង្គម និងនយោបាយ តាមរយៈប្រព័ន្ធផ្សព្វផ្សាយចម្រុះ ដូចជាការបោះពុម្ពផ្សាយ, វិទ្យុ, ទូរទស្សន៍, ប្រព័ន្ធអនឡាញ។ |
| ៥២ | Proprietary Information | ព័ត៌មានជាប់កម្មសិទ្ធិ | ព័ត៌មានរបស់វិស័យឯកជន ដែលគាត់ចាត់ទុកថាជាព័ត៌មានសម្ងាត់ ។ |
| ៥៣ | Public Domain Information | ព័ត៌មានសាធារណៈ | ព័ត៌មានដែលអាចផ្សព្វផ្សាយជាសាធារណៈ (មិនសម្ងាត់) ។ |
| ៥៤ | Public Participation | ការចូលរួមរបស់ប្រជាពលរដ្ឋ | សំដៅដល់ការចូលរួមចំណែករបស់ប្រជាពលរដ្ឋក្នុងសកម្មភាពនានាពាក់ព័ន្ធនឹងបញ្ហាសេដ្ឋកិច្ចនិងសង្គម តាមរយៈការប្រើប្រាស់ឧបករណ៍ឌីជីថល។ |
| ៥៥ | Respect and Understanding | ការគោរព និងការយោគយល់ | សំដៅលើការចេះគោរពនិងយោគយល់ចំពោះភាពខុសគ្នានៅក្នុងក្រុមឬវិស័យផ្សេងៗគ្នា ដូចជា វប្បធម៌, សាសនា, ភេទ, វណ្ណៈក្នុងសង្គម។ |
| ៥៦ | Social Media | បណ្តាញផ្សព្វផ្សាយសង្គម | ការប្រើប្រាស់កម្មវិធីបណ្តាញផ្សព្វផ្សាយព័ត៌មានសង្គមលើអ៊ីនធឺណិត ដើម្បីភ្ជាប់ទំនាក់ទំនងជាមួយមិត្តភក្តិ គ្រួសារ មិត្តរួមការងារ ឬ អតិថិជន ។ |
| ៥៧ | Virtual Reality (VR) | បច្ចេកវិទ្យាតថភាពនិម្មិត ឬ វីអ៊ែ | បរិស្ថានពិតភពនិម្មិតដែលបង្កើតដោយកុំព្យូទ័រ លើរូបភាពបីវិមាត្រដែលអាចត្រូវបានធ្វើអន្តរកម្មនៅក្នុងនោះដូចជាក់ស្តែង ឬ ជារូបវន្ត ដោយអ្នកប្រើប្រាស់ប្រើឧបករណ៍អេឡិចត្រូនិកពិសេសដូចជាមួកដែលមានអេក្រង់នៅក្នុង ឬ ស្រោមដៃបំពាក់ឧបករណ៍ចាប់សញ្ញា។ |

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ១២០២១០

ការិយាល័យអង្គការយូណេស្កូប្រចាំទីក្រុងភ្នំពេញ
ផ្ទះលេខ ៣៨ មហាវិថី សម្ដេចសុធារស សង្កាត់ជ័យជំនះ
ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ឆ្នាំ ២០២៤